# ប្រភពនៃការអប់រំក្នុងពិភពលោកសម័យបុរាណ

**The World Roots of Ancient Education**

*ដោយៈ* **បណ្ឌិត សូ សុធីរ**

*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*

*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម រាជបណ្ឌិត្យសភាកម្ពុជា*

**១-ការអប់រំ នៅក្នុងសង្គម ដែលមនុស្ស មិនទាន់ចេះបង្កើតអក្សរ** (Education in the preliterate society)

**ក-ការផ្ទេរវប្បធម៌** (Cultural transmission)

*និទានកថា នៅទីនេះ បានចាប់ផ្តើមពីសម័យដែលមនុស្សមិនទាន់ចេះអាន និងសរសេរ មុនពេលមានការបង្កើតថ្មីនៃការអាន និងការសរសេរ នៅពេលដែលបុព្វបុរស ផ្ទេរវប្បធម៌ដោយផ្ទាល់មាត់របស់គេ ពីជំនាន់មួយទៅជំនាន់មួយទៀត។ គេអាចស្វែងរកឃើញប្រភពដើមកំណើតនៃការសិក្សាមិនផ្លូវការតាមគ្រួសារ និងវាយតម្លៃថា តើមូលហេតុអ្វីបានជាវានៅតែមានឥទ្ធិពល រហូតមកដល់សព្វថ្ងៃនេះ។ ថ្វីបើយើងរស់នៅក្នុងសម័យកាលមួយ ដែលព័ត៌មានត្រូវបានផ្ទុកក្នុងប្រព័ន្ធអេឡិកត្រូនិក និងរក្សាទុកក្នុងកុំព្យូទ័រក៏ដោយ ក៏ការពិនិត្យមើលការអប់រំនៅសម័យដែលមនុស្ស មិនទាន់ចេះអាន និងសរសេរ អាចជួយឱ្យយើងយល់ដឹងពីមូលហេតុដែលសាលារៀន ជាញឹកញាប់មិនព្រមផ្លាស់ប្តូរនៅពេល ដែលគេបណ្តុះបណ្តាលយុវវ័យនូវបំណិនគង់នៅដ៏សំខាន់* (Essential survival skills)។

**ខ-ការសិក្សាតាមបែបសាកល្បង និងមានកំហុស** (Trial-and-error learning)

*មនុស្ស នៅសម័យដែលមិនទាន់ចេះអាន និងសរសេរ បានប្រឈមមុខនឹងបញ្ហាជំច្រើនលើសលុបនៃការរស់នៅក្នុងបរិស្ថាន ដែលបានទប់ទល់នឹងគ្រោះរាំងស្ងួត និងទឹកជំនន់ សត្វសាហាវ និងការវាយប្រហារពីក្រុមសត្រូវផ្សេងៗ។ តាមការសាកល្បង និងមានកំហុស ពួកគេបានអភិវឌ្ឍបំណិន ដែលមានគង់នៅ ដែលក្នុងអំឡុងពេលមួយ បានក្លាយជាវប្បធម៌គំរូ។*

*ដើម្បីឱ្យវប្បធម៌មានអត្ថិភាព វាត្រូវតែផ្ទេរពីមនុស្សចាស់ ទៅឱ្យកុមារ។ តាមការបង្កើតឱ្យមានវប្បធម៌ កុមារ បានសិក្សាបំណិន និងភាសារបស់ក្រុម ហើយធ្វើឱ្យជ្រួតជ្រាបតម្លៃខាងសាសនា និងសីលធម៌។*

**គ-គោលការណ៍សីលធម៌** (Moral codes)

*ក្នុងអំឡុងពេលមួយ ក្រុមបានអភិវឌ្ឍបំណិនគង់នៅ ហើយបានបន្តបំណិនទាំងនេះទៅឱ្យយុវវ័យ។ ពួកគេបានយកចិត្តទុកដាក់ទៅ*

លើដំណើរឆ្ពង់ ពីកុមារទៅមនុស្សចាស់ជាមួយនឹងរបាំដែលកើតមានជាទម្លាប់ តន្ត្រី និងការសម្ដែងដែលគួរឱ្យរំភើបចិត្ត ដើម្បីបង្កើតនូវអត្តន័យអភិធម្មជាតិដ៏មានឥទ្ធិពល និងបួងសួងដល់ប្រសិទ្ធភាពខាងសីលធម៌។ កុមាររៀនសូត្របទប្បញ្ញត្តិរបស់ក្រុម (Group′s prescriptions) (អាកប្បកិរិយាដែលគួរទទួលយកបាន) ព្រមទាំងការហាមឃាត់ ឬអ្វីដែលគេហាមមិនឱ្យប៉ះ ឬប្រើប្រាស់ (Proscriptions or taboos)។

**ឃ-ប្រពៃណីផ្ទាល់មាត់** (Oral tradition)

ដោយខ្វះខាតផ្នែកសំណេរ ឬការកត់ត្រាក្នុងអតីតកាល សង្គមដែលមិនទាន់មានសំណេរ និងការអាន ពឹងផ្អែកទៅលើប្រពៃណីដែលធ្វើដោយមាត់ទទេ គឺការនិទានរឿង (Storytelling) ដើម្បីផ្ទេរមរតកវប្បធម៌របស់គេ (Cultural heritage)។ មនុស្សចាស់ ឬបព្វជិត ជាញឹកញាប់ជាមនុស្ស ដែលមាននិស្ស័យខាងនិទានរឿង ច្រៀង ឬសូត្រការនិទានរឿងនៃប្រវត្តិអតីតរបស់ក្រុម។ ដោយផ្សំជំនឿសាមញ្ញ (Myths) និងរឿងព្រេង(Legends)ប្រពៃណីដែលធ្វើដោយមាត់ទទេ បាននិទានប្រាប់មនុស្សក្មេងៗ អំពីវីរជនរបស់ក្រុម ជ័យជំនះ និងការបរាជ័យ។ ចម្រៀង និងរឿងនិទាន បានជួយដល់យុវវ័យ សិក្សាភាសានិយាយរបស់ក្រុម និងអភិវឌ្ឍនៃការគិតអរូបី (Abstract thinking) អំពីកាល និងលំហ។

**ខ-ការនិទានរឿង** (Storytelling)

រឿងនិទាន និងការនិទានរឿង នៅតែជាល្បិចដ៏សំខាន់ និងការចូលរួមផ្នែកអប់រំ នាពេលសព្វថ្ងៃ ជាពិសេស នៅមត្តេយ្យ និងថ្នាក់បឋមសិក្សា។ តាមរយៈរឿងនិទាន កុមារទទួលបានបទពិសោធពីវប្បធម៌របស់គេ ហើយនិងវីរបុរសរឿងនិទាន និងប្រវត្តិរបស់ខ្លួន។

**ច-អក្ខរកម្ម**(Literacy)

ក្នុងនាមជាអ្នកបង្កើតឧបករណ៍ មនុស្សបានបង្កើត និងប្រើប្រាស់លំពែង (Spears) ព្វថៅ និងឧបករណ៍ផ្សេងទៀត ជាឧទាហរណ៍នៃបច្ចេកវិទ្យាជំនាន់ដើមបង្អស់។ ស្រដៀងគ្នានេះ ក្នុងនាមជាអ្នកប្រើប្រាស់ភាសា មនុស្សបានបង្កើត និងបានប្រើប្រាស់យ៉ាងប៉ិនប្រសប់នូវសញ្ញាទាំងឡាយ។ ដោយបានចាប់ផ្ដើមបញ្ជាក់បង្ហាញសញ្ញាទាំងនេះ ក្នុងសញ្ញាទាំងឡាយ អក្សររូប និងអក្សរ ហើយនិងការបង្កើតភាសាសរសេររាប់បញ្ចូលទាំងការលោតផ្លោះ ខាងវប្បធម៌ដ៏ធំធេង ចំពោះការចេះអាន និងសរសេរ ហើយបន្ទាប់មក គឺការអប់រំ។

ក្របខណ្ឌសកលមួយ នៃការនិយាយយោងដល់នេះ នឹងជួយអ្នកឱ្យយល់ដឹងនូវចលនាពិភពលោក ដើម្បីអភិវឌ្ឍសាលារៀនក្នុងសង្គមអក្ខរកម្ម។ ព្រោះហេតុដូច្នេះហើយ ការបង្កើតជាប្រវត្តិសាស្ត្រ បានចាប់ផ្ដើមជាមួយនឹងចក្រភពចិន និងឥណ្ឌាបុរាណ។

## ២-ការអប់រំតាមអរិយធម៌ចិនបុរាណ

(Education in the Ancient Chinese Civilization)

*ប្រវត្តិសាស្ត្រអរិយធម៌ចិនដ៏យូរអង្វែង និងឥទ្ធិពលដ៏ធំធេង ផ្តល់នូវជម្រៅការយល់ដឹងដ៏សំ ខាន់ទៅជាការវិវត្តការអប់រំ។ ដោយមានចំនួនប្រជាជនដ៏ច្រើនបំផុតក្នុងពិភពលោក ប្រទេសចិនសម័យទំនើប គឺជាអំណាចសកលដ៏សំខាន់មួយ។ តាមប្រវត្តិសាស្ត្រ ចិន ជាអតីតចក្រភពដ៏ធំមួយ ដែលអរិយធម៌របស់ខ្លួន បានឈានដល់កម្រិតកំពូលបំផុតខាងផ្នែកការអភិវឌ្ឍនយោបាយ សង្គម និងអប់រំ។ ចក្រភពនោះ បានគ្រប់គ្រងទៅដោយសន្តតិវង្ស* (Dynasties) *ជាបន្តបន្ទាប់អស់រយៈពេលជាង ៤០សតវត្ស ពីឆ្នាំ២២០០មុនគ.ស. ដល់ឆ្នាំ ១៩១២*[1]*នៃគ.ស.។ ប្រពៃណីអប់រំជាច្រើន ជាពិសេស ខុងជឺនិយម ដែលមានប្រភពពីចក្រភពចិន នៅតែមានឥទ្ធិពលដល់សព្វថ្ងៃ។*

*មរតកអប់រំនៅចិន បានបង្ហាញនូវការតស៊ូប្រឹងប្រែងជាខ្លាំង ដើម្បីរក្សានូវនិរន្តរភាពវប្បធម៌ ដែលមិនអាចបំបែកបាន។ ប្រៀបដូចជាមនុស្សជាច្រើន ចិនសម័យដើម មានភាពប្រកាន់ពូជសាសន៍ ហើយជឿថា ភាសា និងវប្បធម៌របស់គេ មានភាពកំពូលជាងជាតិសាសន៍ណាៗទាំងអស់*[2]*។ ដោយប្រមាថបរទេសថាជាអនារ្យជនជនជាតិចិន មើលតែភាពខាងក្នុង ដោយមើលឃើញតម្លៃតិចតួចនៅក្នុងវប្បធម៌ផ្សេងទៀត។ តាមពិតទៅភាពស្ទាក់ស្ទើររបស់ចក្រភពចិន ដើម្បីសម្របទៅនឹងបច្ចេកវិទ្យា ពីវប្បធម៌ផ្សេងទៀត ធ្វើឱ្យចិននៅដាច់ពីគេ និងចុះទន់ខ្សោយ ហើយត្រឹមសតវត្សទី១៩ រងការឈឺចាប់ពីការកេងប្រវញ្ចពីពួកបរទេស។ ការខិតខំអស់សមត្ថភាពពីរបៀបសម្របទៅនឹងគំនិតថ្មីៗជាពិសេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយនិងការរក្សាវប្បធម៌ផ្ទាល់ខ្លួន នៅតែជាបញ្ហាអប់រំដ៏សំខាន់ នៅក្នុងប្រ ទេសចិនបច្ចុប្បន្ន ហើយនិងក្នុងប្រទេសផ្សេងទៀតផងដែរ។ ការខិតខំរបស់គេ ជួយយើង ឱ្យយល់បានបញ្ហាដែលថា អ្នកក្នុងនាមជាគ្រូ ត្រូវតែសួរខ្លួនឯង៖ តើអ្នកអាចផ្តល់ឱ្យសិស្ស ជាមួយនឹងការវាយតម្លៃ ចំពោះសមិទ្ធផលវប្បធម៌ និងវិទ្យាសាស្ត្រអតីតកាល ព្រមទាំងបើកចំហ ចំពោះការផ្លាស់ប្តូរវប្បធម៌ និងសង្គមឬទេ? អ្វីជាទំនាក់ទំនង រវាងនិរន្តរភាពវប្បធម៌និងការផ្លាស់ប្តូរ ហើយការអប់រំជំរុញដល់ទំនាក់ទំនងនិរន្តរភាពវប្បធម៌ និងការផ្លាស់ប្តូរមួយ ឬផ្សេងទៀតយ៉ាងដូចម្តេច?*

### ២-១-ការអប់រំតាមបែបខុងជឺ

(Confucian education)

#### ក-ភាពស្មោះត្រង់នៅក្នុងក្រុម

(Group loyalty)

[1]Edward Shaughnessy, *China: Empire and civilization* (New York: Oxford University Press, 2000).

[2]Roxann Praznik, *Dialogues Across Civilization: Sketches in World History from the Chinese and European experiences* (Boulder, Colo.: Westview HarperCollins, 1996

មនុស្សជាច្រើន ជាពិសេសក្នុងប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង សិង្ហបុរី ឱ្យតម្លៃទៅលើខុងជឺ (៥៥១-៤៧៩មុនគ.ស.) ថាជាទស្សនវិទូដ៏ល្បីបំផុតរបស់ពិភពលោក និងជាគ្រូបង្រៀន។ អស់រយៈពេលជាង២០០០ឆ្នាំ ប្រព័ន្ធសីលវិទ្យារបស់ខុងជឺ ដោយមានការសង្កត់ធ្ងន់ទៅលើវិន័យបុគ្គល ភាពស្មោះត្រង់ចំពោះគ្រួសារ និងក្រុម និងតម្រូវការ សម្រាប់ភាពស្របគ្នាខាងនយោបាយ និងសង្គម បានបង្កើតរូបរាងការអប់រំ និងអរិយធម៌ចិន[3]។

**ខ-តម្រូវការសម្រាប់ភាពចុះសម្រុងនឹងគ្នា** ( Need for harmony )

ខុងជឺ បានរស់នៅក្នុងអំឡុងពេលមានសង្គ្រាមរវាងរដ្ឋនានា (The warring states period) នៃប្រវត្តិសាស្ត្រចិន ដែលជាសម័យកាលមួយនៃភាពចលាចលវឹកវរ (Chaotic turmoil) អំពើក្បត់ (Treachery) និងទំនាស់។ មេទ័ពដែលមានការប្រកួតប្រជែង(Rival warlords) ដោយប្រើប្រាស់ភាពឈ្លាសវៃ ចិត្តវៀចវេរ (Duplicity) និងកម្លាំងដូចសត្វតិរច្ឆាន (Brute force) បានតស៊ូប្រយុទ្ធ ដើម្បីអំណាច។ សន្ធិសញ្ញាផ្សេងៗ ត្រូវបានគេបង្កើតឡើង ហើយបន្ទាប់មក មិនត្រូវបានគេយកមកអនុវត្ត។ អំពើស៊ីសំណូកសូកប៉ាន់ (Bribery) ធ្វើឱ្យពួកគេពេញចិត្តជាខ្លាំង ការលួចធ្វើឃាត (Assassi- nations) គឺជារឿងធម្មតា។ ដើម្បីឆ្លើយតប ទៅនឹងសម័យកាលបែបនេះ ខុងជឺ បានបង្កើតទស្សវិជ្ជាអប់រំនិងសីលវិទ្យា ដើម្បីស្តារសន្តិភាព និងភាពចុះសម្រុងគ្នា នៅក្នុងប្រទេសចិន។ ដោយជឿជាក់ថាចំណេះដឹងអាចជំនួសកម្លាំង គាត់បានបង្កើតសាលារៀនមួយ ដែលគាត់អាចអប់រំមន្ត្រីរដ្ឋាភិបាល នាពេលអនាគត ដើម្បីគ្រប់គ្រងប្រទេសចិនដោយយុត្តិធម៌ ភាពត្រឹមត្រូវ និងសណ្តាប់ធ្នាប់។

**គ-ទម្លាប់ និងមារយាទ** ( Rituals and manners )

សម្រាប់ខុងជឺ គោលដៅឧត្តុង្គឧត្តមរបស់ការអប់រំ គឺត្រូវអភិវឌ្ឍមនុស្ស ដែលមានអត្តចរិតថ្លៃ ថ្នូរ ដែលតាមការសិក្សាដោយយកចិត្តទុកដាក់ និងជាបន្តបន្ទាប់ ទទួលបានចំណេះដឹងចាំបាច់ ដើម្បីអនុវត្តតាមរបៀបមធ្យោបាយមួយ ដែលនាំទៅដល់ចិត្តមេត្តា (Benevolence) ជាជាងអំពើហិង្សា (Violence)។ តាមការស្វែងរកការកាត់បន្ថយអកុលតា ដែលបណ្តាលឱ្យមានការផ្លាស់ប្តូរភ្លាមៗនោះ ខុងជឺ បានរៀបចំចាត់ចែងប្រព័ន្ធអប់រំ និងសីលវិទ្យា នៅជុំវិញការសិក្សាពីរបៀបសង្កេត ទម្លាប់និងរបៀបរបប ដែលគ្រប់គ្រងទំនាក់ទំនងមនុស្ស តាមឋានានុក្រមសង្គម។ ឧត្តមគតិរបស់គាត់នៃទំនាក់ទំនងតាមឋានានុក្រម អាចត្រូវបានពិពណ៌នា ថាជាកាំជណ្តើរសីលវិទ្យា ដែលមនុស្សកំពុងតែឈរ នៅលើកាំនីមួយៗ ត្រូវបានភ្ជាប់ទៅនឹងមនុស្ស ដែលកំពុងតែឈរ នៅខាងលើ និងខាងក្រោម។ មនុស្សរាល់គ្នា តាម

[3] See Peimin Ni, *On Confucius* (Belmont, Calif.: Wadsworth, 2002) and Jennifer Oldstone More, Confucianism (Oxford and New York: Oxford University Press, 2002).

ឋានានុក្រម គួរតែដឹងយ៉ាងច្បាស់លាស់នូវឋានៈរបស់ខ្លួន និងការទទួលខុសត្រូវ ហើយនិងរបៀបដ៏សមរម្យនៃការប្រព្រឹត្ត ចំពោះមនុស្សផ្សេងទៀត។

**ឃ-ឋានានុក្រម** ( Hierarchy )

ក្នុងនាមជាគ្រូបង្រៀនម្នាក់ តើអ្នកនឹងជួយសិស្សរបស់ខ្លួន ដើម្បីឱ្យអភិវឌ្ឍទំនាក់ទំនង និងតម្លៃមនុស្សជាវិជ្ជមានយ៉ាងដូចម្ដេច? តើតម្លៃទាំងនេះ នឹងឆ្លុះបញ្ចាំងស្តង់ដារប្រពៃណី ឬវានឹងមិនមានដែនកំណត់? បញ្ញត្តិនៃទំនាក់ទំនងសីលវិទ្យា តាមឋានានុក្រមមាន ការអនុវត្តជាសំខាន់ សម្រាប់ការអប់រំ ជាពិសេស ការបង្កើតអត្តចរិត។ បញ្ញត្តិរបស់ខុងជឺ នៃទំនាក់ទំនងតាមឋានានុក្រម ដែលបុគ្គលមួយចំនួនមានភាពខ្ពង់ខ្ពស់ ហើយអ្នកផ្សេងទៀត មានតូចតាច ខុសគ្នាយ៉ាងខ្លាំងពីគំនិតសាមញ្ញរបស់យើងសព្វថ្ងៃ នៃទំនាក់ទំនងមនុស្សដោយផ្អែកលើសមភាព។

តាមលក្ខខណ្ឌសមភាពបុគ្គល ដែលចូលរួមក្នុងទំនាក់ទំនងមួយ កំណត់ជាបន្តបន្ទាប់នូវទំនាក់ទំនង និងបង្កើតការបើកចំហថ្មីៗចំពោះគ្នាទៅវិញទៅមក ហើយជាញឹកញាប់ បង្កើត ឬបង្កើតឡើងវិញនូវដែនកំណត់ទាំងឡាយ។ ការអប់រំអត្តចរិតនៅក្នុងស្ថានភាពនៃសមភាព នាំទៅដល់បញ្ញត្តិសីលវិទ្យា ដែលយើងគួរប្រព្រឹត្តដល់បុគ្គលម្នាក់ៗ ថាមានភាពស្មើៗគ្នា ហើយយើងគួរតែគោរព និងវាយតម្លៃនូវភាពខុសគ្នារបស់គេពីយើង។

ផ្ទុយទៅវិញ សីលវិទ្យាខុងជឺ បង្កើតគំរូជាក់លាក់នៃអាកប្បកិរិយា ជាជាងភាពបត់បែន ឬទន់ ភ្លន់។ មនុស្ស ត្រូវបានអនុញ្ញាតឱ្យមានកម្រិតគោរពផ្សេងៗគ្នា ដោយផ្អែកទៅលើតំណែង ឬឋានៈ និងសមិទ្ធផល។ ការអប់រំអត្តចរិត មានន័យថា រៀនពីតួនាទី នៅក្នុងបណ្ដាញនៃទំនាក់ទំនង ដែលបង្កើតបានសហគមន៍ និងដើម្បីបំពេញអាកប្បកិរិយា តួនាទី ទៅតាមបញ្ញត្តិ ដែលធានាដល់ភាពចុះសម្រុងគ្នានៅក្នុងសង្គម។

ពីព្រោះតែការផ្លាស់ប្ដូរភាពថ្មីប្លែកៗ នវានុវត្តន៍ អាចនាំដល់ក្ដីមិនរំពឹងទុកមុន ហើយ ការផ្លាស់ប្ដូរដោយមិនរំពឹងទុកមុន គឺជាបញ្ហាសង្គមមួយនោក្នុងពេលនេះ ខុងជឺ បានផ្អែកប្រព័ន្ធសីលវិទ្យា ទៅតាមប្រពៃណី។ ការប្រតិបត្តិដ៏ពិតប្រាកដមួយ ឬអាកប្បកិរិយា ដែលរួមចំណែកដល់ការរក្សាសន្តិភាព សន្តិសុខ និងភាពរំងាប់ចិត្ត (Tranquility) ក្នុងអតីតកាល នៃតម្លៃដែលត្រូវបានស្រោបក្នុងរបៀបតាមទម្លាប់នៃការប្រព្រឹត្ត ហើយត្រូវបានផ្ទេរ និងប្រតិបត្តិ ដោយមនុស្សនាពេលបច្ចុប្បន្ន។ ដោយយោងទៅតាមខុងជឺ "មនុស្សម្នាក់ ដែលមានតម្លៃជាគ្រូ ត្រូវចេះដឹងពីអ្វីដែលថ្មី តាមការរក្សាចំណេះដឹងថ្មីៗ ក្នុងចិត្តនូវអ្វីៗ ដែលគាត់បានចេះដឹងរួចមកហើយ[4]។

[4] Confucius, *The Analects*, Book II, in D. C. Lau, Introduction, *The Analects*, trans. D. C. Lau (New York: Penguin Books, 1979), p. 64.

**ខ-ការគោរព ចំពោះគ្រូ** (Respect for teachers)

*នៅប្រទេសចិន ទំនាក់ទំនងគ្រូ-សិស្ស ដូចទំនាក់ទំនងផ្សេងទៀតដែរ គឺមានភាពល្បីល្បាញ និងត្រូវមានភាពជាក់លាក់។ សិស្ស ត្រូវគោរពគ្រូរបស់គេជាខ្លាំង និងខ្ពង់ខ្ពស់។ សិស្សផ្ទាល់របស់ខុងជឺ បានហៅគាត់ថា លោកម្ចាស់* (The master)*។ ការគោរពចំពោះការ អប់រំ ការសិក្សា និងគ្រូ បានក្លាយជាលក្ខណៈពិសេសដ៏សំខាន់នៃការអប់រំ ក្នុងប្រទេសចិន និងអាស៊ីអាគ្នេយ៍ ដែលជាកន្លែងដែលខុងជឺ បានក្លាយជាបញ្ញវន្តចម្បង និងកម្លាំងអប់រំ*[5]*។*

**២-២-ការរួមចំណែករបស់ចិន ចំពោះការអប់រំពិភពលោក** (Chinese's contri- bution to world education)

*សារៈសំខាន់នៃការប្រឡង*

*កេរដំណែលអប់រំដ៏សំខាន់ពីចិនបុរាណ គឺប្រព័ន្ធការប្រឡងថ្នាក់ជាតិ។ គរុវិទូចិន បានអភិវឌ្ឍការប្រឡងបែបសរសេរតាមការយល់ដឹង ដើម្បីវាយតម្លៃសមត្ថភាពសិក្សារបស់សិស្ស។ សិស្សបានត្រៀមរៀបចំដើម្បីប្រឡង តាមការសិក្សាអក្សរសិល្ប៍ចិនបុរាណ និងអត្ថបទខុងជឺ ជាមួយគ្រូនៅសាលាតាមព្រះវិហារ ឬព្រះបរមរាជវាំង។ ការប្រឡងសង្កត់ធ្ងន់ ទៅលើការចងចាំដោយទន្ទេញព័ត៌មាន ជាជាងដោះស្រាយបញ្ហាជាក់ស្តែង។ ដំណើរការប្រឡង ដូចជាសង្គម បានដំណើរការតាមឋានានុក្រម និងតាមការជ្រើសរើស។ សិស្ស ត្រូវតែប្រឡងជាប់នូវលំដាប់នៃការប្រឡងដ៏លំបាក តាមលំដាប់កើនឡើង។ ប្រសិន បើគេប្រឡងធ្លាក់ គេនឹងត្រូវបណ្តេញចេញពីដំណើរការនោះ*[6]*។ នៅក្នុងសម័យកាលនោះ មានតែអ្នកប្រ- ឡងដល់ទីបញ្ចប់តិចតួចតែប៉ុណ្ណោះ អាចទទួលបានតំណែងសេវាកម្មស៊ីវិលជាន់ខ្ពស់បំផុតរបស់ចក្រភពចិន។ ប្រព័ន្ធអប់រំ និងការប្រឡង ត្រូវបានរក្សាទុកឱ្យទាំងស្រុងតែមនុស្សប្រុសវណ្ណៈខ្ពស់ប៉ុណ្ណោះ។ ស្ត្រី ដែលមិនអាចទទួលតំណែងក្នុងរដ្ឋាភិបាលនោះ មិនមានសិទ្ធិចូលរៀនផងដែរ។*

**៣-ការអប់រំតាមអរិយធម៌ឥណ្ឌាបុរាណ**

**ក-សមតាវប្បធម៌**

*ដូចជាប្រទេសចិន ឥណ្ឌា មានអរិយធម៌បុរាណមួយ។ អរិយធម៌ទាំងឡាយ ដែលមាននៅតាមជ្រលងភ្នំ ទន្លេ លូតលាស់បានល្អ នៅតាមច្រាំងទន្លេឥណ្ឌុស*(Indus) *របស់ឥណ្ឌា នៅ*Mohenjodaro and Harrapa *ពី៣០០០មុនគ.ស. ទៅដល់១៥០០មុនគ.ស.។ ប្រវត្តិអប់រំរបស់ឥណ្ឌា បានលាតត្រដាងនូវគំរូនៃការឈ្លានពានជាទូទៅ ដោយអ្នកលុកលុយ ឈ្លានពានដែលបន្ទាប់មក ដោយការប៉ះទង្គិចខាងវប្បធម៌ជាមួយជនជាតិដើម ហើយបន្ទាប់មកគឺការស្តារសមតាវប្បធម៌សង្គម។ នៅក្នុងសមតាវប្បធម៌នេះ អ្នកឈ្លានពាន ត្រូវបានគេស្រូបទាញយកទៅជាវប្បធម៌ឥណ្ឌា ដែលនៅពេលជាមួយគ្នា*

[5] T.R. Reid, *Confucius Lives Next Door: What living in the East Teaches Us about Living in the West* (New York: Vintage Press, 2000).

[6] Conrad Schriokauer, *A Brief History of Chinese Civilization* (New York: Harcourt Brace Jovanovich, 1991), pp. 57, 124, 128.

នោះ ជនជាតិដើម បានខ្ចីគំនិតពីអ្នកឈ្លានពាន លុកលុយមួយចំនួន[7]។

**ខ-ប្រវត្តិសង្ខេប**

នៅក្នុងចំណោមអ្នកលុកលុយជំនាន់ដើមរបស់ឥណ្ឌា គឺពួកអារ្យ៉ង់ (The Aryans) ជាបុព្វបុរសនៃអម្បូរជនភាគច្រើន ដែលនិយាយភាសាហិណ្ឌូ (Hindi-speaking majority) របស់ឥណ្ឌា ដែលបានចូលលុកលុយឥណ្ឌាក្នុង ១៥០០ឆ្នាំមុនគ.ស. ហើយបានបង្ខំការត្រួតត្រាពួកស្រុកដើមដ្រាវិទ (The indigenous Dravidian inhabitants)។ បន្ទាប់មក មានពួកអ្នក កាន់សាសនាអ៊ីស្លាម ដែលបានបង្កើតសន្តតិវង្ស Mughulក្នុងសតវត្សទី១៧។ បន្ទាប់មកទៀត ក្នុងសតវត្សទី១៨ ចក្រភពអង់គ្លេស បានត្រួត ត្រាប្រទេសឥណ្ឌា។

ការផ្លាស់ប្តូរវប្បធម៌ ដែលបាននាំមកដោយពួកអារ្យ៉ង់ បានបង្កើតឥទ្ធិពលអប់រំ និងសង្គមដ៏មានអំណាចដែលបានបន្តមកដល់ពេលសព្វថ្ងៃ។ ពួកអារ្យ៉ង់ បាននាំមកនូវសាសនាព្រាហ្មណ៍ និងវណ្ណៈសង្គមដ៏ខ្ពង់ខ្ពស់របស់គេ ដែលគេបានហៅថា ប្រព័ន្ធវណ្ណៈ(The caste system)។

**គ-សាសនាឥណ្ឌូ**

សាសនាឥណ្ឌូ ដែលជាកម្លាំងដ៏មានឥទ្ធិពលមួយ នៅក្នុងប្រទេសឥណ្ឌានោះ រួមបញ្ចូលទាំងជំនឿសាសនាដ៏ទូលំទូលាយមួយ និងទម្លាប់ដ៏ល្អិតល្អន់ទាំងឡាយ។ សាសនាឥណ្ឌូសង្កត់ធ្ងន់ទៅលើការផ្លាស់ប្តូរនៃព្រលឹង (Transmigration of souls) គឺព្រលឹងរបស់មនុស្សម្នាក់ បានឆ្លងកាត់ការចាប់បដិសន្ធិជាថ្មី (Reincarnations) ជាច្រើន ហើយតំណែងរបស់មនុស្សម្នាក់ នៅក្នុងកម្រិតលោកធាតុ អាស្រ័យទៅលើមនុស្សម្នាក់ ប្រកាន់នូវករណីកិច្ច និងទម្លាប់បានល្អយ៉ាងដូចម្តេច។ ការចាប់បដិសន្ធិជាថ្មី (Reincarnations) បញ្ចប់តែនៅពេលដែលព្រលឹង បានឈានដល់កម្រិតខាងផ្លូវចិត្តឬស្មារតីខ្ពស់បំផុត ហើយត្រូវបានស្រូបទាញឡើងវិញដោយព្រហ្ម (Brahma) ដែលជាអំណាចមកពីអាទិទេព[8]។

**ឃ-ប្រព័ន្ធវណ្ណៈ**

វណ្ណៈដែលជាប្រភពដើម មាន៤គឺៈ

-ព្រាហ្មណៈ (Brahmins) = អ្នកអប់រំដែលជាបព្វជិត (Priest-educators)

-ក្សត្រិយៈ (Kshatriyas) = អ្នកគ្រប់គ្រង (rulers) ចៅក្រម (Judges) និងអ្នកចម្បាំង (Warriors)

-វៃស្សៈ (Vaishyas) = ពាណិជ្ជករ ម្ចាស់ដី (Merchants)

-សូទ្រៈ (Sudras)= កសិករ ទាសករ (The farmers)។

ស្រទាប់វណ្ណៈក្រោមគេបំផុត គឺអ្នកដែលគេមិនឱ្យប៉ះពាល់ ឬមនុស្សក្រៅវណ្ណៈ(The

[7] See Stanley A. Wolport, Herman Kulke and Dietmar Rothermunt, *A history of India* (New York: Routlege, 1998

[8] Arvrin Sharma, ed. *The Study of Hinduism* (Columbia: University of South Carolina Press, 2003; also see Mehdi Nakosteen, *The History and Philosophy of Education* (New York: Ronald Press, 1965), pp.23-30

untou- chables) ដែលធ្វើការងារថោកទាបបំផុត (The most menial work)។ ចល័តភាពសង្គម មិនមានទាល់តែសោះ។ មនុស្សនៅតែស្ថិតក្នុងវណ្ណៈដដែល តាំងពីពេលដែលគេបានកើតមក ហើយបានរៀនសូត្រនូវករណីកិច្ច និងតួនាទីរបស់ខ្លួន ដោយត្រាប់តាមឪពុកម្តាយ និងមនុស្សចាស់ផ្សេងទៀត។ ការសិក្សាអប់រំ ទុកឱ្យតែមនុស្សវណ្ណៈខ្ពស់តែប៉ុណ្ណោះ ជាពិសេស គឺពួកព្រាហ្មណៈ។ ដោយចាត់ទុកថា ការរើសអើងវណ្ណៈជាការខុសច្បាប់ ឥណ្ឌាសម័យទំនើប បានបង្ខំឱ្យមានសកម្មភាពវិជ្ជមានសម្រាប់សមាជិក វណ្ណៈទាប។ ទោះជាយ៉ាងនេះក្តី ការរើសអើង នៅតែកើតមាន។

### ៣-១-ការវិវត្តនៃការអប់រំឥណ្ឌា

ការអប់រំនៅឥណ្ឌា បានឆ្លុះបញ្ចាំងនូវគំរូជាប្រវត្តិសាស្ត្រទូទៅនៃការរស់នៅ លាយឡំនឹងវប្បធម៌ផ្សេងៗគ្នា។ សាលារៀនសម័យដើម បានឆ្លុះបញ្ចាំងនូវការផ្លាស់ប្តូរវប្បធម៌ ដែលនាំមកដោយពួកអារ្យ៉ន។ ឥណ្ឌាបុរាណ មានប្រភេទសាលារៀនដូចតទៅ៖

ក-វេទ: (Veda = Knowledge)

1-សាលារៀនពួកព្រាហ្មណ៍ សម្រាប់វណ្ណៈបព្វជិត សង្កត់ធ្ងន់ទៅលើសាសនា ទស្សនវិជ្ជា។ វេទ (Vedas), the Bhagavad Gita (& The Upanishads) និងឧបនិស័ទ សៀវភៅសាសនាដ៏ពិសិដ្ឋរបស់ព្រាហ្មណ៍ ពណ៌នាគោលដៅនៃជីវិតថា ជាការស្រាវជ្រាវសច្ចភាពខាងស្មារតីសកល។ ការស្វែងរកសច្ចភាព ដែលអ្នកអប់រំឥណ្ឌាជឿជាក់នោះ គឺថា ការទាមទារឱ្យមានការតាំងភាវនាដ៏មានវិន័យ។ ការតាំងភាវនាអព្យោហារិកនាសម័យទំនើប និងយោគៈ ធ្វើតាមគោលការណ៍ឥណ្ឌាបុរាណ ដើម្បីស្វែងរកសច្ចភាព និងភាពស្ងប់ស្ងៀម (Serennity) ខាងស្មារតី។

2-Tols ជាសាលារៀនដែលមានតែមួយបន្ទប់ ដែលមានតែគ្រូបង្រៀនតែម្នាក់ បង្រៀនសាសនា និងច្បាប់។

3-សាលារៀនវាំង ទទួលខុសត្រូវដោយព្រះអង្គម្ចាស់ បង្រៀនអក្សរសាស្ត្រ ច្បាប់ និងរដ្ឋបាល។

ខ-សាលារៀន និងការបង្រៀន

ទស្សនវិជ្ជាអប់រំឥណ្ឌា ដោយបានសង្កត់ធ្ងន់ទៅលើសាសនា បានបញ្ញត្តទំនាក់ទំនងគ្រូសិស្សយ៉ាងសមរម្យ។ គ្រូ ត្រូវតែលើកទឹកចិត្តសិស្ស (ឱ្យចេះគោរពជីវិត?) និងចេះស្រាវជ្រាវរកសច្ចភាព។ សិស្សត្រូវតែគោរពគ្រូ ដែលជាប្រភពនៃគតិបណ្ឌិត ហើយគ្រូត្រូវតែចេះទប់អារម្មណ៍ កុំធ្វើឱ្យសិស្សអា ម៉ាស់មុខ[9]។

គ-Mughuls

សន្តតិវង្ស Mughulsដែលបង្កើតឡើងក្រោយពេលមានការចូលលុកលុយនៃពួកមូស្លីម បាននាំមកនូវសាសនាអ៊ីស្លាម និងទស្សនវិជ្ជាពួកPersian និងអារ៉ាប់ វិទ្យាសាស្ត្រ អក្សរសាស្ត្រ

[9] Nandish Patel, A Comparative Exposition of Western and Vedic Theories of the Institution of Education, *International Journal of Educational Management 8* (1994), pp-9-14

តារាសាស្ត្រ(Astronomy) គណិតវិទ្យា វេជ្ជសាស្ត្រ សិល្បៈ តន្ត្រី និងស្ថាបត្យកម្ម (Architecture)។

ឃ-ការចូលមកដល់នៃពួកអង់គ្លេស

ត្រឹមពេលដែលជនជាតិអង់គ្លេស បានចូលមកដល់ប្រទេសឥណ្ឌា នៅចុងសតវត្សទី ១៨ សាលារៀនរបស់ពួកឥណ្ឌាដឹកនាំដោយពួកឥណ្ឌូ ឬមូស៊្លីម ឬដោយនិកាយតូចៗ ដូចជា ពុទ្ធសាសនិកជន Jains, and Parsis។ មានតែ ១០% នៃកុមារឥណ្ឌា ភាគច្រើនក្មេងប្រុស បានចូលរៀន។ សាលារៀនជាន់ខ្ពស់ឥណ្ឌា ដឹកនាំដោយពួកព្រាហ្មណ៍ដោយសង្កត់ធ្ងន់លើ អក្សរសិល្ប៍ខាងសាសនា គណិតវិទ្យា តារាសាស្ត្រ និងវេយ្យាករណ៍សំស្ក្រឹត។ សាលារៀនពួកមូស៊្លីមហៅថា Madrassahs ត្រូវបានផ្សារភ្ជាប់ទៅនឹងព្រះវិហារម៉ូស (Mosques) ហើយនិងសង្កត់ធ្ងន់ទៅលើវេយ្យាករណ៍ និងគម្ពីរកូរ៉ាន (Korans)[10]។

នៅពេលដែលចក្រភពអង់គ្លេសបានបង្កើតការគ្រប់គ្រង តាមបែបអាណានិគម នៅក្នុងប្រទេសឥណ្ឌា ពួកគេ បានប៉ះទង្គិចនឹងអរិយធម៌ ជាមួយនឹងភាសា និងសាសនាជាច្រើន។ ពួកអង់គ្លេសដោយឱ្យតម្លៃទៅលើភាសាអង់គ្លេស ជាងភាសាកំណើតរបស់ឥណ្ឌា បានបង្កើតភាសាអង់គ្លេសជាភាសាផ្លូវការ សម្រាប់រដ្ឋាភិបាលនិងពាណិជ្ជកម្មហើយនិងបាន បង្កើតសាលារៀន ដែលប្រើប្រាស់ភាសាអង់គ្លេស ដើម្បីបណ្តុះបណ្តាលជនជាតិឥណ្ឌា សម្រាប់មុខតំណែងនៅក្នុងសេវាកម្មស៊ីវិល ដែលគ្រប់គ្រងដោយជនជាតិអង់គ្លេស។

**៣.២-ការរួមចំណែករបស់ឥណ្ឌាចំពោះការអប់រំពិភពលោក**

កេរដំណែលរបស់ឥណ្ឌាបុរាណ ចំពោះពិភពលោក គឺជាគំរូនៃរបៀបអប់រំ អាចជួយដល់អរិយធម៌មួយអស់រយៈពេលជាច្រើនសតវត្ស។ តាមរយៈការធ្វើឱ្យជ្រួតជ្រាបវប្បធម៌និងការសម្របសម្រួលឡើងវិញនោះ អរិយធម៌ឥណ្ឌា បានស្ថិតនៅរហូតដល់បច្ចុប្បន្ន។ នៅ ក្នុងបរិយាកាសសព្វថ្ងៃ ដែលមានភាពតានតឹងខាងសាសនា និងជាតិសាសន៍ ដែលចេះតែមានការកើនឡើងនោះ ឥណ្ឌាបានប្រឈមមុខនឹងការប្រឆាំងយ៉ាងខ្លាំងក្នុងការធ្វើឱ្យជ្រួតជ្រាប និងគោរពវប្បធម៌ផ្សេងៗ។ សហរដ្ឋអាម៉េរិក និងជាតិដែលមានពហុភាពខាងវប្បធម៌ ផ្សេងៗប្រឈមមុខនឹងការប្រឆាំងដូចៗគ្នា។ ស្ថានភាពរបស់ឥណ្ឌាបានលាតត្រដាងពីរបៀប ដែលវណ្ណៈ ដូចជាជាតិសាសន៍និយម នៅក្នុងសហរដ្ឋអាម៉េរិក ត្រូវបានធ្វើឱ្យមាននិរន្តរភាពដោយសង្គម និងការអប់រំ ប៉ុន្តែ ឥឡូវនេះ កំពុងត្រូវបានកែលំអតាមរយៈលំនាំការអប់រំ។ លោកអ្នកក្នុងនាមជាគ្រូបង្រៀនម្នាក់ ទំនងជានឹងត្រូវបានប្រឆាំងតាមភាពផ្សេងៗនៃសិស្សរបស់អ្នក។ តើអ្នកនឹងប្រើពហុវប្បធម៌និយម ជាមធ្យោបាយជំរុញភាពផ្សេងៗគ្នាខាងវប្បធម៌ ក្នុងថ្នាក់រៀនរបស់អ្នក?

[10] Lawrence James, Raj: The Making and Unmaking of British India (New York: St. Martin’s Press, 1998).

## ៤-ការអប់រំ នៅប្រទេសអេហ្ស៊ីបបុរាណ

*អេហ្ស៊ីបបុរាណ ដែលជាប្រទេសមួយមានអរិយធម៌ដំបូងបង្អស់ក្នុងពិភពលោកនោះ បានអភិ វឌ្ឍ ដូចជាចំនួនប្រជាជនសម័យដើមផ្សេងទៀត ជាវប្បធម៌ជ្រលងភ្នំ និងទន្លេ។ ដោយសារតែទឹក ដែលកំពុងតែទ្រទ្រង់ដល់ជីវិតនៃទន្លេនីល(៦,៨៥៣គម)នោះ ក្រុមកសិកម្មបានបង្កើតការតាំងទីលំនៅជាភូមិតូចៗ រៀបចំទៅជារាជាណាចក្រតាមកុលសម្ព័ន្ធ នៅតាមច្រាំងទន្លេ។ ប្រហែលជា៣០០០មុនគ.ស. រាជាណាចក្រទាំងនេះ បានពង្រឹងខ្លួនឱ្យទៅជាចក្រភពដ៏ធំមួយ ដែលតាមពិតទៅ ក្លាយទៅជាប្រទេស ដែលមជ្ឈមណ្ឌលសក្តានុពលខាងនយោបាយ និងការរៀបចំដ៏ខ្ពង់ខ្ពស់។*

*លោកធាតុដែលមិនប្រែប្រួល*

*គោលការណ៍នយោបាយ និងសាសនាអេហ្ស៊ីបដ៏សំខាន់ បានអះអាងថា ផារ៉ាអុង (Pharaoh) ដែលជារាជិរាជនោះ (Emperor) មានប្រភពពីអាទិទេព។ បញ្ញត្តិនៃរាជាធិរាជភាពផ្តល់នូវស្ថិរភាពខាងនយោបាយ អប់រំ វប្បធម៌ និងសង្គមទៅដល់ចក្រភពអេហ្ស៊ីប ដោយផ្តល់មូលដ្ឋានគ្រឹះសមស្របតាមអភិ ធម្មជាតិ។ ចំណេះដឹង និងតម្លៃ ត្រូវបានគេមើលឃើញថាជាការឆ្លុះបញ្ចាំងលោកធាតុអនន្តមិនផ្លាស់ប្តូរ និងមានរបៀបរៀបរយ។ បញ្ញត្តិនៃបព្វជិតរាជាក៏ផ្តល់ផងដែរនូវឋានៈយ៉ាងខ្ពស់នៃវរជន ដែលជាបព្វជិត និងអំណាចដ៏ខ្លាំង នៅក្នុងអេហ្ស៊ីប។ ប្រព័ន្ធអប់រំពង្រឹងឋានៈ និងអំណាចដោយបង្កើតផ្ទាំវរជន ដែលជាបព្វជិតនៃវប្បធម៌របស់រដ្ឋ។*

### ៤.១-ការយកចិត្តទុកដាក់ធម្មចក្រនិងអាណាចក្រ

*ទាក់ទិននឹងការអប់រំ ជនជាតិអេហ្ស៊ីបមានទំនាក់ទំនងនឹងលោកិយ និងមិនមែនលោកិយ។ ទោះបីជាមានអភិធម្មជាតិពីមុន ពួកគេ ក៏បានអភិវឌ្ឍបច្ចេកវិទ្យា ដើម្បីនាំទឹកទន្លេនីល រៀបចំ និងស្ថាបនាប្រាសាទពីរ៉ាមីដដ៏ច្រើន។ ដើម្បីគ្រប់គ្រង និងការពារចក្រភពដ៏ធំទូលាយរបស់គេ ពួកគេបានសិក្សាជំនាញក្នុងការគ្រប់គ្រងរដ្ឋ*(Statecraft) *និងការយកចិត្តទុកដាក់របស់ពួកគេ ជាមួយការរក្សាសពមិនឱ្យរលួយ* (Mummification) *ដែលបាននាំឱ្យពួកគេ សិក្សាវេជ្ជសាស្ត្រ កាយវិភាគវិទ្យា និងការអប់សព* (Embalming)*។ ជនជាតិអេហ្ស៊ីប ក៏បានអភិវឌ្ឍផងដែរនូវប្រព័ន្ធនៃការសរសេរអក្សរ គឺអក្សររូប* (Hiero- glyphic script) *ដែលជួយឱ្យពួកគេបង្កើត និងផ្ទេរវប្បធម៌ការសរសេរអក្សរ។*

### ក-សាលារៀន តាមព្រះវិហារ និងវាំង

*ចក្រភពអេហ្ស៊ីប ទាមទារឱ្យមានការិយាធិបតេយ្យ ដែលមានការអប់រំ ដើម្បីប្រមូល និងកត់ត្រាបន្ទុក។ ត្រឹមឆ្នាំ២៧០០មុនគ.ស. ជនជាតិអេហ្ស៊ីប មានប្រព័ន្ធសាលារៀន តាមព្រះវិហារ និងវាំងយ៉ាងទូលំទូលាយ។ មុខងារសាលារៀនមួយ ត្រូវបណ្តុះបណ្តាលមនុស្សឱ្យចេះបង្កើតការកត់ត្រា*(Scribes) *ដែល ភាគច្រើននៃពួកគេគឺ*

ជាបញ្ជិត ក្នុងការអាន និងសរសេរ។ សាលារៀនជាញឹកញាប់ គឺជាផ្នែកមួយនៃអគារជាច្រើនផ្គុំគ្នា នៅតាមព្រះវិហារ ដែលធ្វើឱ្យរីកចម្រើនដល់ទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងការអប់រំក្នុងប្រព័ន្ធ និងសាសនា[11]។ ក្រោយពេលទទួលបានការអប់រំជាលើកដំបូង ក្មេងប្រុសបានសិក្សាអក្សរសាស្ត្រ ដែល សមស្របទៅនឹងវិជ្ជាជីវៈ នាពេលអនាគតរបស់គេ។ សាលារៀនជាន់ខ្ពស់ ពិសេស បានបង្កើតឡើង សម្រាប់បញ្ជិតពិតប្រាកដ មន្ត្រីរដ្ឋាភិបាល និងគ្រូពេទ្យ។

**ខ-ការអប់រំមនុស្សឱ្យចេះកត់ត្រា**

នៅក្នុងសាលារៀន ដែលបង្ហាត់មនុស្សឱ្យចេះកត់ត្រា សិស្ស រៀនសរសេរអក្សររូប តាមការចម្លងឯកសារនៅលើក្រដាសម្យ៉ាង ដែលផលិតចេញពីដើមត្រែង ឬបបុស ដែលដុះនៅតាមដងទន្លេនីល។ គ្រូហៅឱ្យសិស្សកត់ត្រានូវអ្វីដែលគេបានឮ។ គោលដៅ គឺត្រូវបង្កើតឡើងវិញ នូវការកត់ត្រាអត្ថបទឱ្យបានត្រឹមត្រូវដូចដើម។ ជាញឹកញាប់ សិស្ស ស្រែកសូត្រដដែលៗនូវអត្ថបទខ្លីៗ រហូតដល់ពួកគេចាំបានច្បាស់លាស់។ អ្នកទាំងឡាយ ដែលបានរៀនពូកែ ត្រូវបានសិក្សាគណិតវិទ្យា តារាសាស្ត្រ សាសនា កំណាព្យ អក្សរសិល្ប៍ វេជ្ជសាស្ត្រ និងស្ថាបត្យកម្ម។

**៤.២-វិវាទជាប្រវត្តិសាស្ត្ររបស់អេហ្ស៊ីប**

**ក-ការបកស្រាយតាមប្រពៃណី**

តួនាទីអេហ្ស៊ីបបុរាណ នៅក្នុងការបង្កើតអរិយធម៌លោកខាងលិច បានក្លាយទៅជាវិវាទ នៅឆ្នាំ៣៣២មុនគ.ស. ប្រទេសអេហ្ស៊ីប ត្រូវបានចូលលុកលុយដោយ Alexander the Great និងបានបង្កើតជាអរិយធម៌ Hellenistic ដែលត្រូវបានបង្កើតដោយវប្បធម៌ក្រិកបុរាណ។ ការបកស្រាយប្រវត្តិសាស្ត្រដោយសន្មត គឺថា អរិយធម៌អេហ្ស៊ីបបុរាណ គឺការកាន់អំណាចផ្តាច់ការនិយមដ៏យូរ ហើយកេរដំណែលវប្បធម៌ចម្បង គឺវិមានស្ថាបត្យកម្មដ៏ធំធេងរបស់ខ្លួន។ ការបកស្រាយនេះ បានបង្ហាញឱ្យឃើញវប្បធម៌របស់ក្រិក ជាពិសេសប្រជាធិបតេយ្យក្រុងអាថែន ជាទីកន្លែងចាប់កំណើតនៃអរិយធម៌លោកខាងលិច។

**ខ-ទ្រឹស្តីរបស់ប៊ែរណាល** (Bernal's Theory)

ការបកស្រាយប្រកបដោយវិវាទជាខ្លាំងដោយ Martin Bernal អះអាងថា ជនជាតិក្រិកបានខ្ចីបញ្ញត្តិជាច្រើន អំពីរដ្ឋាភិបាល ទស្សនវិជ្ជា សិល្បៈ និងវិទ្យាសាស្ត្រពីអេហ្ស៊ីបបុរាណ។ លើសពីនេះទៀត ជនជាតិអេហ្ស៊ីប មានទីតាំងភូមិសាស្ត្រ នៅអាហ្វ្រិកខាងជើង គឺជាជនជាតិអាហ្វ្រិក និងជាប្រភពវប្បធម៌លោកខាងលិច គឺជនជាតិអាហ្វ្រិកនេះឯង[12]។ ថ្វីបើគេបានទទួលស្គាល់អន្តរកម្ម រវាងជនជាតិអេហ្ស៊ីប និងក្រិក

[11] James Mulhern, *A History of Education, A Social Interpretation* (New York: Ronald Press, 1959), pp.55-79

[12] Martin Bernal, *Black Athena: The Afroasiatic Roots of Classical Civilization: The Fabrication of Ancient Greece 1785-1985* (New Brunswick, N. J.,: Rutgers University Press, 1987), pp.2-3

ការរិះគន់របស់ Bernal អះអាងថា ការសង្កត់យ៉ាងធ្ងន់នៃឥទ្ធិពលរបស់អេហ្ស៊ីប ទៅលើក្រិកបុរាណ។ នៅពេលដែលប្រវត្តិវិទូ បន្តពិភាក្សាបញ្ហានេះ រេបកគំហើញ ដែលគ្រាន់តែជាការស្មាបស្មង់នោះ ចង្អុល បង្ហាញថា ទំនាក់ទំនងអេហ្ស៊ីប-ក្រិក ជាពិសេស នៅកោះCrete នាំយកមកប្រើប្រាស់ ដោយជនជាតិក្រិកទៅជាចំណេះដឹងជនជាតិអេហ្ស៊ីបដូចជា គណិតវិទ្យា និងទម្រង់សិល្បៈអេហ្ស៊ីប។

**គ-អតីតកាលគឺជាប្រភពនៃអំណាច**

វិវាទប្រវត្តិសាស្ត្រ ដែលគួរឱ្យចង់ដឹងមានខ្លឹមសារជាមនោគមវិជ្ជាដ៏សំខាន់។ អ្នកណាក៏ដោយ ដែលបានបកស្រាយពីអតីតកាល ទទួលឥទ្ធិពលនៃការបំភ្លឺឱ្យច្បាស់លាស់ និងបង្កើតរូបរាងដល់បច្ចុប្បន្ន។ ក្នុងករណីពិសេសវិវាទ មានទំនាក់ទំនង ដល់ការពិភាក្សា នាពេលបច្ចុប្បន្ន អំពីមជ្ឈមណ្ឌលអាហ្វ្រិកនិយម និងកម្មវិធីសិក្សាពីទ្វីបអាហ្វ្រិក នៅសាលារៀនទាំងឡាយ។ នៅផ្នែកបន្ទាប់មកទៀត យើងត្រឡប់ទៅមើលជនជាតិក្រិកបុរាណ។ ថាតើ ទទួលបានឥទ្ធិពលដោយផ្ទាល់ ឬមិនផ្ទាល់ ដោយជនជាតិអេហ្ស៊ីបជនជាតិក្រិក បន្តការរក្សាទីកន្លែងដ៏សំខាន់ក្នុងប្រវត្តិនៃការអប់រំ។ យ៉ាងក៏ដោយ ចូររក្សាក្នុងចិត្តថា វប្បធម៌ ជាប្រវត្តិភាគច្រើនបំផុត បានខ្ចីពីគ្នា ទៅវិញទៅមក តាមរបៀបជាច្រើនបែប ហើយដើមកំណើត នៃគំនិតជនជាតិក្រិក អាចត្រូវបានរកឃើញ នៅអេហ្ស៊ីប ឬកន្លែងផ្សេងទៀត។

**៥-ការអប់រំ តាមអរិយធម៌ក្រិក និងរ៉ូម៉ាំងបុរាណ**

ប្រវត្តិអប់រំនៃក្រិក និងរ៉ូមបុរាណ បានបំភ្លឺដល់ដើមកំណើតនៃបញ្ហា ដែលតស៊ូជាច្រើន ដែលគ្រូនាពេលសព្វថ្ងៃ ត្រូវប្រឈមមុខ។ ក្នុងចំណោមបញ្ហាអប់រំ ជនជាតិក្រិក និងរ៉ូម៉ាំង ដែលបានពិភាក្សាគឺ អ្វីគឺពិត ល្អ ល្អស្អាត? អ្នកណា ជាគំរូដ៏មានតម្លៃ សម្រាប់កុមារ ត្រាប់តាម? តើការអប់រំ បង្កើតពលរដ្ឋល្អឬទេ? តើការអប់រំ គួរតែឆ្លើយតបទៅនឹងការផ្លាស់ប្តូរខាងសង្គម សេដ្ឋកិច្ច និងនយោបាយដូចម្តេច?

**ក-ការអប់រំតាមបែបហូមែរ** ( Homeric Education )

ជំនាន់មនុស្សទាំងឡាយ បានធ្វើឱ្យរំភើបនូវចំណោទសួរនៃកំណាព្យវីរកថារបស់ Homer គឺIliad and Odyssey។ ដោយបានបង្ហាញខ្លួន នៅប្រហែលឆ្នាំ១២០០មុនគ.ស. វីរកថារបស់ Homer ជួយឱ្យជនជាតិក្រិក កំណត់ខ្លួនគេ និងវប្បធម៌របស់គេ។ ប្រៀបដូចជាពិធីទាំងឡាយ នៅក្នុងសង្គមមនុស្ស មិនទាន់ចេះអាន និងសរសេរនោះ ការពិពណ៌នា គួរឱ្យរំភើបចិត្តរបស់Homer នៃអ្នកធ្វើចម្បាំងជាតិក្រិកប្រ ឆាំងនឹងTrojans ត្រូវបានយកមកប្រើជា គោលបំណងអប់រំដ៏សំខាន់៖

1-វាបានរក្សាវប្បធម៌ តាមការផ្ទេរវា ពីមនុស្សចាស់ទៅមនុស្សក្មេង។

2-វាបានអប់រំអត្តសញ្ញាណវប្បធម៌ជនជាតិក្រិក ដោយផ្អែកលើប្រភពរឿងនិទាន និងប្រវត្តិសាស្ត្រ។

3-វាបង្កើតអត្តចរិតយុវវ័យ[13]។

Agamemnon, Ulysses, Achilles និងអ្នកចម្បាំងផ្សេងទៀត បានដើរតួគួរឱ្យរំភើបនូវទំហំជីវិតវីរបុរស។ ដោយប្រើវីរបុរសទាំងនេះ ជាតួនាទីគំរូ ជនជាតិក្រិកក្មេងៗ បានសិក្សា អំពីតម្លៃដែលបានបង្កើតជីវិតឱ្យមានតម្លៃអាកប្បកិរិយាដែលបានរំពឹងចេញពីវីរជនសង្គ្រាម និងអនិបុណភាពអត្តចរិត ដែលនាំទៅដល់ការចុះរាសីរបស់គេ។

**ខ-ការអប់រំភាពជាពលរដ្ឋ**

ក្រិកបុរាណ បានធ្វើឱ្យចម្រើនដល់តួនាទីការអប់រំ ក្នុងការបង្កើតពលរដ្ឋល្អ។ ដូចជាជនជាតិអាម៉េរិក ទំនងជាមិនយល់ស្របទៅលើរូបមន្តជាក់លាក់ សម្រាប់អប់រំពលរដ្ឋល្អ ដូច្នេះជនជាតិក្រិក ក៏បានពិភាក្សាទៅលើបញ្ហានេះ។ មិនដូចមហាចក្រភពចិន និងអេហ្ស៊ីប ក្រិកបុរាណ បានចែកជាផ្នែកតូចៗ ហើយជាញឹកញាប់ប្រកួតប្រជែងរដ្ឋដែលជាទីក្រុងដែល ដូចជាអាថែន និងស្ប៉ាត (Athens and Sparta) បានកំណត់ន័យការទទួលខុសត្រូវ និងសិទ្ធិពលរដ្ឋខុសគ្នាៗ។ ក្រោយពេលធ្វើការពិសោធជាមួយទម្រង់ រដ្ឋាភិបាលផ្សេងៗគ្នាអាថែន បានក្លាយជារដ្ឋប្រជាធិបតេយ្យ ដែលសង្កត់ធ្ងន់ទៅលើការទទួលខុសត្រូវ ជាសាធារណៈនៃពលរដ្ឋរបស់ខ្លួន។ ស្ប៉ាត ដែលជាគូប្រជែងរបស់អាថែន គឺជារដ្ឋប្រើអំណាចផ្តាច់ការខាងយោធា (Authoritarian military dictatorship)[14]។ ដើម្បីប្រៀបធៀបរដ្ឋាភិបាលខុសគ្នា រដ្ឋជាទីក្រុងនីមួយៗ មានប្រភេទនៃការអប់រំពលរដ្ឋរបស់ខ្លួន។

**គ-ការបង្កើតការអប់រំ និងការអប់រំក្នុងប្រព័ន្ធ**

ជនជាតិក្រិក ទទួលស្គាល់សារៈសំខាន់នៃការអប់រំ ដែលកំពុងមានអន្តរកម្ម គឺការធ្វើឱ្យមានការជ្រួតជ្រាប និងការចូលរួមក្នុងវប្បធម៌ទាំងមូលរបស់រដ្ឋជាទីក្រុង ជាមួយការអប់រំក្នុងប្រព័ន្ធ។ តាមរយៈការបង្កើតឱ្យមានការអប់រំ យុវវ័យជនជាតិក្រិក ត្រូវបានត្រៀមរៀបចំ ដើម្បីឱ្យក្លាយជាពលរដ្ឋនៃសង្គមរបស់គេ។ ការអប់រំក្នុងប្រព័ន្ធ ផ្តល់ចំណេះដឹងចាំបាច់ ដើម្បីបំពេញក្តីសង្ឃឹមនៃជីវិតល្អក្នុងសង្គមទាំងមូលថែមទៀត។ ឧទាហរណ៍ ពួកអាថែន ជឿថា មនុស្សដែលមានសេរីភាព ចាំបាច់ត្រូវការការអប់រំដែលប្រកបដោយសេរីភាព ដើម្បីបំពេញករណីកិច្ចពលរដ្ឋព្រមទាំងអភិវឌ្ឍជាបុគ្គល[15]។ ផ្ទុយទៅវិញ ស្ប៉ាត ប្រើការអប់រំក្នុងប្រព័ន្ធ សម្រាប់ការបណ្តុះបណ្តាលយោធា។

**ឃ-តួនាទីនៃទាសករ**

សង្គមក្រិក ជាប់ពាក់ព័ន្ធទៅតាមផ្នែកជាមួយទាសករ។ ភាគច្រើននៃទាសករ ដែលរួមបញ្ចូលទាំងស្ត្រី និងកុមារ គឺជាឈ្លើយសង្គ្រាម ឬអ្នកទាំងឡាយ ដែលបានចោលទោសដោយ

[13] Louis Goldman, Homer, Literacy, and Education, *Educational Theory* (Fall 1989), pp. 391-400.
[14] Nigel M. Kennel, *The Gymnasium of Virtue: Education and Culture in Ancient Sparta* (Chapel Hill: Univer- sity of South Carolina Press, 1995)
[15] Kevin Robb, *Literacy and Paideia in Ancient Greece* (New York: Oxford University Press, 1994).

ច្បាប់ចំពោះសេរីភាពៗ ទោះបីជាទាសករ ដែលមានការអប់រំតិចតួច បានបង្រៀនកូនសិស្សទោល ជាអ្នកមានក្នុងក្រុងអាថែនក៏ដោយ ក៏ទាសករភាគច្រើនត្រូវបានគេបណ្តុះបណ្តាល ដើម្បីឱ្យចេះធ្វើកសិកម្ម ឬបំណិនខាងពាណិជ្ជកម្ម។ ពួកអាថែន ជឿជាក់ថា ការអប់រំប្រកបដោយសេរីភាពសមរម្យ សម្រាប់មនុស្សសេរី គឺឥតមានប្រយោជន៍ សម្រាប់ទាសករ។ ការពិភាក្សាសម័យទំនើបរវាងអ្នកគាំទ្រនៃការអប់រំសេរី និងវិជ្ជាជីវៈ បានវិលត្រឡប់ ទៅរកភាពខុសគ្នានៃពួកអាថែន រវាងការបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ពួកទាសករ និងការអប់រំសេរី សម្រាប់ពលរដ្ឋសេរី។

**ខ-ការអប់រំស្ត្រី**

នៅក្នុងសង្គមក្រិក ដែលគ្របដណ្តប់ដោយពួកបុរស មានតែស្ត្រីក្នុងករណីលើកលែងភាគតិចប៉ុណ្ណោះ ដែលទទួលបានការអប់រំក្នុងប្រព័ន្ធខ្ពះៗ។ ក្នុងក្រុងអាថែន ស្ត្រីមានសិទ្ធិខាងសេដ្ឋកិច្ច និងស្របច្បាប់តាមដែនកំណត់បំផុត ហើយស្ត្រីភាគតិចបំផុត បានចូលរៀន។ ស្ត្រីក្មេងៗ ដែលមានសំណាងជាង ទទួលបានការបង្រៀន នៅនឹងផ្ទះ ពីគ្រូបង្រៀនសិស្សទោល។ ស្ត្រីផ្សេងទៀត ដូចជាបព្វជិត ជាស្ត្រីនៃនិកាយសាសនាផ្សេងៗ បានសិក្សាទម្លាប់ខាងសាសនា នៅសាលារៀន តាមព្រះវិហារ។ ផ្ទុយទៅវិញ ស្ត្រីក្មេងៗរបស់ពួកស្ប៉ាត ទទួលបានការបណ្តុះបណ្តាលខាងយោធា និងកីឡាកាយសម្ព័ន្ធ ដើម្បីរៀបចំពួកគេជាម្តាយ ដែលមានសុខភាពនៃទាហានស្ប៉ាតនាពេលអនាគត។

**៥-១-ពួកសូហ្វីស** ( The Sophists )

នៅក្នុងសតវត្សទី៥មុនគ.ស. សេដ្ឋកិច្ចដែលកំពុងផ្លាស់ប្តូរ បាននាំមកនូវគំរូខាងអប់រំ និងសង្គមថ្មី ទៅដល់ក្រិក ជាពិសេស អាថែន។ វណ្ណៈអភិជន (Aristocracy) ដែលមានវ័យចំណាស់ បានប្តូរកន្លែង ដោយវណ្ណៈពាណិជ្ជកម្មថ្មី ដែលមានផលចំណេញពីការរីកដាលនៃពួកអាថែន និងអាណានិគមកម្ម។ ការផ្លាស់ប្តូរសេដ្ឋកិច្ចសង្គមនេះ បង្កើតបានលក្ខខណ្ឌសម្រាប់ពួកសូហ្វីស។

**ក-គ្រូដែលដើរត្រាច់ចរ**

ពួកសូហ្វីស ដែលជាក្រុមអ្នកអប់រំដែលធ្វើដំណើរ បានអភិវឌ្ឍវិធីបង្រៀនថ្មី ដើម្បីបង្រៀនវណ្ណៈពាណិជ្ជកម្មថ្មី តាមបំណិនការនិយាយសាធារណៈ។ ភាពគ្រប់គ្រាន់ក្នុងសិល្បៈនៃការថ្លែងសុន្ទរកថាសំ ខាន់ខ្លាំងណាស់ក្នុងសង្គមប្រជាធិបតេយ្យ ដូចជាអាថែន ដែលវា ត្រូវបានគេប្រើ ដើម្បីបញ្ចុះបញ្ចូលកិច្ចប្រជុំ និងព្រះរាជបរិវារឱ្យពេញចិត្ត[16]។

**ខ-វេយ្យាករណ៍ តក្កវិទ្យា និងវោហារសាស្ត្រ**

ពួកសូហ្វីស ស្វែងរកអភិវឌ្ឍបំណិនទំនាក់ទំនងរបស់សិស្ស ដើម្បីឱ្យគេអាចក្លាយជានីតិពន្ធ និងអ្នកគាំទ្រដ៏មានជោគជ័យ។ មុខវិជ្ជាសំខាន់បំផុតរបស់ពួកសូហ្វីស គឺតក្កវិទ្យា

[16] The Philosophy of the Sophists, **http:www.radicalacademy.com/philosophists.htm**

វេយ្យាករណ៍ និងវោហារ សាស្ត្រ ជាប្រធានបទដែលត្រូវបានអភិវឌ្ឍ នៅពេលក្រោយមក ទៅជាសិល្បៈសេរី។ **តក្កវិទ្យា គឺជាវិធាននៃអំណះអំណាងដ៏ត្រឹមត្រូវ** បានបណ្ដុះបណ្ដាលនិស្សិតឱ្យចេះរៀបចំការបង្ហាញរបស់គេបានច្បាស់លាស់ ហើយនិង**វេយ្យាករណ៍ បានអភិវឌ្ឍថាមពលនៃការប្រើប្រាស់ភាសាឱ្យមានប្រសិទ្ធភាព។ វោហារសាស្ត្រ ដែលជាការសិក្សាសម្ដីបញ្ចុះបញ្ចូល** មានសារៈសំខាន់ពិសេស សម្រាប់អ្នកថ្លែងសុន្ទរកថា នាពេលអនាគត។

**គ-ចំណេះដឹងជាឧបករណ៍**

ពួកសូហ្វីស អះអាងថា គេអាចអប់រំសិស្សរបស់គេ ឱ្យទទួលបានការពិភាក្សាជា សាធារណៈ តាមការបង្រៀនពួកគេ៖

1-របៀបប្រើប្រាស់ចិត្តវិទ្យាក្នុងហ្វូងមនុស្ស ដើម្បីដឹងពីអ្វីដែលនឹងសុំ ឬអំពាវនាវដល់ ទស្សនិក ជន។

2-របៀបរៀបចំអំណះអំណាង ដែលប្រកបដោយការជឿជាក់ និងបញ្ចុះបញ្ចូល។

3-បំណិនក្នុងការនិយាយជាសាធារណៈ គឺដោយដឹងថា អ្វីជាពាក្យ ឧទាហរណ៍ និងប្រភេទនៃហេតុផល ដើម្បីយកមកប្រើប្រាស់ឱ្យទទួលបានការពិភាក្សាឬករណីរឿងណាមួយបានជោគជ័យ។

ប្រសិនបើពួកគេនៅរស់ដល់សព្វថ្ងៃ ពួកសូហ្វីស ទំនងជាអះអាងថា គោលវិធីអប់រំរបស់ពួកគេផ្ដល់ឱ្យមនុស្សនូវអ្វីដែលគេចង់បាន គឺបំណិនរៀបចំគំនិត និងដើម្បីបង្ហាញពួកគេដោយមានប្រសិទ្ធភាពខ្លាំងពេករហូតដល់មនុស្ស នឹងត្រូវបានគេបញ្ចុះបញ្ចូលឱ្យទទួលយកការប្រកាសរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ការរិះគន់របស់ពួកសូហ្វីស បានចោទប្រកាន់ពួកគេ ពីការសង្កត់ធ្ងន់ផ្នែកបច្ចេកទេសដែលទទួលបានការអះអាង ទៅលើការស្វែងរកសច្ចភាពនៃបញ្ហាដែលនៅជិត។ ឬហៀបនឹងកើតឡើង។

ពួកសូហ្វីស គឺប្រៀបដូចជាអ្នកបង្កើតរូបភាពសម័យទំនើប ដែលប្រើប្រាស់ប្រព័ន្ធឃោសនា ដើ ម្បីក្ដោបយកបេក្ខជនខាងនយោបាយ និងវិស្សុតជន(Celebrities)។ ថ្វីបើការពិភាក្សាខាងនយោបាយនាពេលសព្វថ្ងៃ និងការពិភាក្សាបេក្ខជន កើតមានឡើងតាមទូរទស្សន៍ជាជាងរស់នៅក្នុងមជ្ឈមណ្ឌលក្រុងអាថែននោះ ពួកសូហ្វីស នឹងអះអាងពីបច្ចេកទេសរបស់ពួកគេ នៅតែមានភាពរឹងមាំ។ វានៅតែមានសារៈសំខាន់ ដើម្បីយល់ដឹងពីទស្សនិកជន ដើម្បីអំពាវនាវសុំពីតម្រូវការរបស់គេ និងដើម្បីប្រើប្រាស់ការបញ្ចុះបញ្ចូលប្រកបដោយបំណិនដើម្បីធ្វើឱ្យពួកគេជឿជាក់។ ពួកគេ គួរតែពិចារណាទៅលើក្រុម ដែលមាន ការផ្ដោតអារម្មណ៍ ការស្ទង់មតិមហាជនជាសាធារណៈ ហើយនិងឧបករណ៍បញ្ចុះបញ្ចូល ដែលមានប្រយោជន៍កំពុងផ្សព្វផ្សាយជាអវិជ្ជមាន។

**ឃ-វិធី**Protagoras

តាមមធ្យោបាយជាច្រើន ពួកសូហ្វីស បានអភិវឌ្ឍគោលវិធីទំនើបគួរទាក់ទាញ

អារម្មណ៍ ចំពោះការអប់រំ។ Protagoras (485-414 B.C.) ដែលជាពួកសូហ្វីសដ៏សំខាន់បំផុតម្នាក់នោះ បានអភិវឌ្ឍល្បិចបង្រៀន៥ជំហាន ប្រកបដោយប្រសិទ្ធភាពខ្ពស់[17]៖

1-ផ្ដល់សុន្ទរកថា (Speech) ដ៏ចំណាន ដើម្បីឱ្យសិស្សយល់ដឹងថា គ្រូរបស់គេ អាចធ្វើអ្វីនៅពេលដែលគាត់មានបំណងនឹងបង្រៀនគេ។ សុន្ទរកថានេះ ក៏ផ្ដល់ឱ្យគេនូវគំរូមួយ អាចអនុវត្តតាម។

2-ឱ្យសិស្សពិនិត្យមើលសុន្ទរកថាដ៏អស្ចារ្យ នៃវាគ្មិនដ៏ល្បីល្បាញ (Famous orators) ដើម្បីបរិយាយគំរូទាំងឡាយ ដែលអាចយកទៅប្រើប្រាស់បាន។

3-សិក្សាមុខវិជ្ជាគន្លឹះនៃតក្កវិទ្យា វេយ្យាករណ៍ និងវោហារសាស្ត្រ។

4-ផ្ដល់ការប្រតិបត្តិសុន្ទរកថា (Oration) ដែលគាត់អាចវាយតម្លៃ ដើម្បីផ្ដល់ព័ត៌មាន ត្រឡប់ទៅសិស្ស។

5-វាគ្មិន ដែលជាសិស្ស ផ្ដល់សុន្ទរកថាជាសាធារណៈ។

វិធីរបស់ Protagoras ប្រដូចកម្មវិធីអប់រំគ្រូនាពេលសព្វថ្ងៃ ដែលក្នុងនោះ អនាគតគ្រូបង្រៀន សិក្សាសិល្បៈសេរី និងមុខវិជ្ជា ដែលទាក់ទងនឹងវិជ្ជាជីវៈ សិក្សាល្បិចបង្រៀនផ្សេងៗ និងធ្វើកម្មសិក្សា នៅក្រោមការដឹកនាំពីគ្រូ ដែលជួយសហប្រតិបត្តិការប្រកបដោយ បទពិសោធ។

**ខ-សច្ចភាពស្ថិតស្ថេរ ឬសច្ចភាពមិនរឹងមាំ**

ការបង្ហាញខ្លួនរបស់ពួកសូហ្វីស នៅឆាកឱ្យគេមើលឃើញក្នុងសម័យបុរាណ បានលើកឡើងនូវបញ្ហាអប់រំដ៏សំខាន់ ដែលចម្លើយនាំទៅដល់វិវាទរហូតដល់សព្វថ្ងៃនេះ។ ពួក សូហ្វីស គឺជាពួកដែលមានសច្ចភាពខាងសីលធម៌មិនរឹងមាំ (Moral relativists) ដែលបាន អះអាងថា អ្វីដែលយើងចាំបាច់យល់ដឹង អាស្រ័យទៅលើកាលៈទេសៈ ដែលយើងរស់នៅ។ សូក្រាត ប្លាតុង និងអារីស្តូត បានប្រឆាំងនឹងសច្ចភាពមិនរឹងមាំរបស់គេ ហើយបានទទូចចង់បានអត្ថិភាពនៃសច្ចភាពស្ថិតស្ថេរ ដែលយើងត្រូវតែយល់ដឹង។ Isocrates ដែលជាគ្រូសិល្បៈខាងការថ្លែងសុន្ទរកថា បានព្យាយាមដោះស្រាយវិវាទ ដោយនិយាយថា យើងចាំបាច់ត្រូវ យល់ដឹងអ្វីដែលជាការពិត ប៉ុន្តែ ក៏អនុវត្តវាផងដែរ ទៅនឹងស្ថានភាព ដែលយើងរស់នៅ។ យើងនឹងពិភាក្សាទស្សនៈនៃទស្សនវិទូអប់រំទាំង៤នាក់នេះ។

**៥-២-Socrates: ការអប់រំ តាមការស្ង័យពិនិត្យ**

**ក-គោលការណ៍សកល**

មិនដូចជាពួកសូហ្វីស ដែលបានអះអាងថា ចំណេះដឹងអាស្រ័យទៅលើស្ថានភាព ដែលមនុស្សប្រើវា។ សូក្រាត (៤៦៩-៣៩៩មុនគ.ស.)

[17] Edward Schiappa, *Protagoras and Logos: A Study in Greek Philosophy and Rhetoric* (Columbia: University of South Carolina Press, 2003;also see L. Glenn Smith, *Lives in Education: People and Ideas in the Development of Teaching* (Ames, Iowa: Education Study Press, 1984), pp.7-9

ជឿជាក់ថា ចំណេះដឹង គឺត្រូវផ្អែក ទៅលើអ្វីដែលជាសច្ចភាពសកល គឺគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។ គំនិតសូក្រាត មានសារៈសំខាន់ក្នុងប្រវត្តិអប់រំ ពីព្រោះគាត់បានការពារយ៉ាងរឹងមាំថា សេរីភាពខាងការសិក្សា ដើម្បីគិតសួរ និងបង្រៀន។ គាត់ក៏មានសារៈសំខាន់ផងដែរ ក្នុងនាមជាគ្រូរបស់ Plato ដែលក្រោយមកបានធ្វើឱ្យគំនិតរបស់ Socrates ជាច្រើនមានលក្ខណៈជាប្រព័ន្ធ[18]។

**ខ-ឧត្តមភាពសីលធម៌**

ទស្សនវិជ្ជា Socrates សង្កត់ធ្ងន់ទៅលើគោលការណ៍សីលវិទ្យា ដែលមនុស្សម្នាក់ គួរតែខិតខំ សម្រាប់ឧត្តមភាពសីលធម៌ រស់នៅដោយភាពវាងវៃ និងធ្វើសកម្មភាពប្រកបដោយវិចារណញ្ញាណ។ Socrates ជឿជាក់ថា ឧត្តមភាពសីលធម៌ មានភាពកំពូលខ្លាំងជាងការបណ្ដុះបណ្ដាលបច្ចេកទេសរបស់ពួកសូហ្វីស។

**គ-តួនាទីគ្រូរបស់សូក្រាត**

បញ្ញត្តិរបស់សូក្រាតនៃគ្រូបង្រៀន ខុសប្លែកពីពួកសូហ្វីស។ គាត់មិនបានជឿថា ចំណេះដឹងឬគតិបណ្ឌិតអាចផ្ទេរពីគ្រូ ទៅសិស្សម្នាក់បានទេពីព្រោះគាត់បានជឿជាក់ថាបញ្ញត្តិ នៃចំណេះដឹងពិត មានពិតមែន តែវាបានកប់បាត់នៅ ក្នុងចិត្តមនុស្ស។ គ្រូត្រូវតែសួរសំណួរ ឱ្យបានត្រឹមត្រូវ ដើម្បីឱ្យសិស្សគិតដោយល្អិតល្អន់អំពីសំណួរសំខាន់ៗ។ ការអប់រំប្រកបដោយសេរីភាពពិតប្រាកដមួយ នឹងក្លោចសិស្ស ស្រាជ្រាវរកគំនិត ដោយនាំទៅដល់ញាណនូវការពិតដែលមាន តែមិនទាន់បញ្ចេញឱ្យឃើញនៅក្នុងចិត្តរបស់គេ។

**ឃ-ស្វ័យពិនិត្យ ការសន្ទនា និងវិធីសូក្រាត**

គោលបំណងអប់រំបែបសូក្រាត គឺត្រូវជួយបុគ្គលឱ្យកំណត់ខ្លួនគេ តាមស្វ័យពិនិត្យ។ តាមរបៀបនេះ បុគ្គលម្នាក់ៗ អាចស្វែងរកការពិត ដែលមានជាសកលក្នុងគ្រប់មនុស្សទាំងអស់។ ក្នុងនាមជាគ្រូម្នាក់ សូក្រាត បានសួរសំណួរនាំមុខដែលក្លោចសិស្ស ដើម្បីស៊ើបអង្កេតនូវការយកចិត្តទុកដាក់របស់មនុស្សតាំងពីយូរ (Perennial human concerns) អំពីអត្ថន័យនៃជីវិត ការពិត និងយុត្តិធម៌។ បន្ទាប់មក សិស្សមានការពិភាក្សាយ៉ាងសកម្ម តែឱ្យមានភាពលំបាក ឬការសន្ទនា ដែលក្នុងនោះសិស្សបញ្ជាក់អះអាង ទិតៀន និងបង្កើតឡើងវិញ នូវបញ្ញត្តិមូលដ្ឋានរបស់ពួកគេ។ ចំពោះសូក្រាត ការសន្ទនា មិនមែន មានន័យថា គ្រាន់តែចែករំលែកគំនិតនោះទេ។ វាមានន័យថា ការឆ្លុះបញ្ចាំង និងការទិតៀនពួកគេ ឱ្យរកឃើញសច្ចភាពជាមូលដ្ឋាន (The underlying truth)។ គោលវិធីនេះនៅតែត្រូវបានគេទទួលស្គាល់ ថាជាវិធីសូក្រាត។ ក្នុងនាមជាគ្រូម្នាក់ អ្នកអាចប្រើវិធីសូក្រាត តាមការសួរសំណួរដល់សិស្ស ដែលបានរៀប ចំជាស្រេច ដើម្បីចម្រាញ់យកការគិតល្អិតល្អន់របស់ពួកគេ ទៅលើបញ្ហាថ្មីៗឬ ជាប្រវត្តិសាស្ត្ររបស់

[18] Gary Alan Scott, Plato's Socrates as Educator (Albany: State University of New York Press, 2000), pp. 1-12. Also see Alven Neiman, Ironic Schooling: Socrates, Pragmatism and the Higher Learning, *Educational Theory* (Fall 1991), pp.371-384

ពួកគេ ឬអំពីស្នាដៃអក្សរសាស្ត្រ ដែលត្រូវបាន ដាក់ឱ្យសិស្សអាន។

ដោយប្រៀបបាននឹងទីផ្សារអាថែន ដែលបានកើតឡើងជាញឹកញាប់នោះ សូក្រាត បានទាក់ទាញក្រុមមនុស្សក្មេងៗ ដែលបានចូលរួមជាមួយគាត់ក្នុងការពិនិត្យដោយល្អិតល្អន់ នៃប្រភេទនៃបញ្ហាទាំងអស់ ដូចជា សាសនា នយោបាយ សីលធម៌ និងសោភ័ណវិទ្យា (Aesthetics)។ ក្នុងនាមជាអ្នករិះគន់ទៅលើសង្គមវិញ សូក្រាត បានបង្កើតសត្រូវដ៏មានឥទ្ធិពល។ ដូច្នេះហើយ ក្នុងពេលឥឡូវនេះ មនុស្សមួយចំនួន ដោយរាប់បញ្ចូលទាំងមនុស្ស ដែលមានឋានៈខ្ពង់ខ្ពស់ផងដែរ បានភ័យខ្លាចថា ការគិតដ៏ល្អិតល្អន់ អាចប្រឆាំងនឹងការងារ របស់ពួកគេ ហើយនាំទៅដល់ចលាចល។ នៅក្នុងឆ្នាំ៣៩៩ មុនគ.ស. ក្រោយពេលបានវិនិច្ឆ័យការចោទប្រកាន់ពីការខ្វះសេចក្តីគោរព(Impiety) ដល់ព្រះជាម្ចាស់ និងអំពើពុករលួយទៅលើយុវជនអាថែន សូក្រាត ត្រូវបានគេកាត់ទោសប្រហារជីវិត (Socrates was condemned to death) ជា កា ត់ទោសមួយ ដែលគាត់ មិនបានប្រកែកតវ៉ា។

### ៥-៣-ប្លាតុង៖ សច្ចភាព និងតម្លៃអនន្ត

#### ក-តថភាព ជាគំនិតសកល និងអនន្ត

ប្លាតុង ជាកូនសិស្សរបស់សូក្រាត(៤២៧-៣៤៦មុនគ.ស.) បានដើរតាមផ្លូវជាអ្នកអប់រំរបស់ គាត់។ ប្លាតុង បានបង្កើតបណ្ឌិត្យសភា ដែលជាសាលារៀនខាងទស្សនវិជ្ជា នៅឆ្នាំ៣៨៧មុនគ.ស.។ គាត់បាននិពន្ធ Protagoras ដែលជាសេចក្តីថ្លែងស្តីអំពីគុណធម៌ និងសាធារណរដ្ឋ និងច្បាប់អភិប្រាយអំពីនយោបាយ ច្បាប់ និងការអប់រំ[19]។ ដោយជំទាស់នឹងសច្ចភាព មិនមានលំនឹងរបស់ពួកសូហ្វីស ប្លាតុងបានអះអាងថា ភាពពិត កើតមាន ពីពិភពមិនប្រែប្រួលនៃគំនិតឥតខ្ចោះ គឺបញ្ញត្តិសកល ដូចជា សច្ចភាព កុសល យុត្តិធម៌ និងសោភណភាព។ ករណីបុគ្គលនៃបញ្ញត្តិទាំងនេះ ដូចដែលវាបានបង្ហាញខ្លួន ចំពោះ វិញ្ញាណរបស់យើង គឺគ្មានអ្វីក្រៅពីការបង្ហាញអសុក្រឹតនៃបញ្ញត្តិសកល និងអនន្ត ដែលមាននៅក្នុងគំនិតដាច់ខាត គឺទម្រង់នៃកុសល។

#### ខ-ការរំឭកពីរឿងអតីតកាល

ទ្រឹស្តីប្លាតុងនៃចំណេះដឹង គឺផ្អែកលើការរំឭកពីរឿងដើម (Reminiscence) គឺជាលំនាំ ដែលបុគ្គលចងចាំគំនិត ដែលមាន តែមិនទាន់បង្ហាញឱ្យឃើញក្នុងចិត្ត។ ការរំឭករឿងដើម អះអាងថា ព្រលឹងមនុស្ស មុនពេលចាប់កំណើត បានរស់នៅក្នុងពិភពខាងស្មារតី គឺជា ប្រភពនៃសច្ចភាព និងចំណេះដឹង។ នៅពេលកើត គំនិតពីកំណើតទាំងនេះ ត្រូវបានទប់ នៅក្នុងគំនិតអនុញ្ញាណ។ ចំពោះប្លាតុង ការសិក្សាមានន័យថា គេអាចរកឃើញឡើងវិញ ឬចងចាំគំនិតឥតខ្ចោះទាំងនេះ[20]។

[19] Devin Stuffer, *Plato's Introduction to the Question of Justice* (Albany: State University of New York Press, 2000).

[20] Gerald L. Gutek, *Historical and Philosophical Foundations of Education: A Biographical Introduction* ( Columbus, Ohio: Merril / Prentice Hall, 2005), pp.37-40.

**គ-សកលនិយម ទល់នឹងសច្ចភាពមិនមានលំនឹង**

មិនដូចសភាពផ្លាស់ប្តូរបានរបស់សច្ចភាព មិនមានលំនឹង សកលនិយម អះអាងថា ស្នាមដិតខាងវិញ្ញាណ ធ្វើឱ្យខុសពីភាពពិត ចំណេះដឹងពិត គឺខាងបញ្ញា មិនផ្លាស់ប្តូរ និងអនន្ត មិនមែនឥន្ទ្រីយារម្មណ៍ទេ។ មិនមានគំនិតណាមួយល្អឥតខ្ចោះ សម្រាប់មនុស្សទាំងអស់ ដោយមិនគិតពីពេល ឬកន្លែងដែលគេរស់នៅ។ ពីព្រោះការពិត នៅតែជាការពិត ការអប់រំ គួរតែមានលក្ខណៈសកល និងមិនប្រែប្រួលផងដែរ។

**ឃ-គំនិតពីកំណើត**

ជំនឿដែលថា គំនិតពីកំណើត មាន តែមិនទាន់បង្ហាញឱ្យឃើញនៅក្នុងចិត្ត មានឥទ្ធិពលខាងអំណាច ទៅលើការអប់រំលោកខាងលិចពីសម័យដើម។ ការអប់រំនៅឥណ្ឌា ក៏បានឆ្លុះបញ្ចាំងជំនឿក្នុងគំនិតពីកំណើត។ ការអប់រំផ្នែកវេទ បានលើកទឹកចិត្តឱ្យមានការតាំងភាវនាដើម្បីរកឱ្យឃើញចំណេះដឹងពីកំណើត។ នៅលោកខាងលិច ទ្រឹស្តីគំនិតពីកំណើត ត្រូវបានប្រឆាំងដោយអ្នកធ្វើកំណែទម្រង់ផ្នែកអប់ រំនាពេលក្រោយមក ដូចជា Locke, Pestalozzi, Dewey និងអ្នកផ្សេងទៀត ដែលគំនិតរបស់គេត្រូវបានសិក្សានៅពេលក្រោយ។ វិវាទផ្នែកអប់រំនាពេលក្រោយជាច្រើនដែលសូម្បីតែប្រយោជន៍នាពេលបច្ចុប្បន្នក្នុងអ្នកស្ថាបនានិយម អាចត្រូវបានគេមើលឃើញថា ជាការអះអាងតប ចំពោះទ្រឹស្តីនៃគំនិតរបស់ប្លាតុងដែរ។

**ខ-សាធារណរដ្ឋ**

វាជាសង្គមប្រកបដោយឧត្តមគតិរបស់ប្លាតុង។ នៅក្នុងសាធារណរដ្ឋរបស់ប្លាតុង គាត់បានរៀបចំគម្រោងផែនការ សម្រាប់សង្គមល្អឥតខ្ចោះមួយ ដែលគ្រប់គ្រងដោយអធិ រាជទស្សនវិជ្ជា ដែលជាវរជនខាងបញ្ញា។ ទោះបីជារដ្ឋ ដែលជាឧត្តមគតិរបស់ប្លាតុង មិនដែលត្រូវបានគេអនុវត្តក៏ដោយ ក៏គំនិតរបស់គាត់ មានប្រយោជន៍ក្នុងការពិពណ៌នា កំណែប្រែថ្មី ដែលជាឧត្តមគតិនៃប្រភេទការអប់រំដ៏ពិតប្រាកដមួយ[21]។ សាធារណរដ្ឋ បានបែងចែក ជាវណ្ណៈ៣៖

1-អធិរាជទស្សនវិជ្ជា៖ អ្នកដឹកនាំដែលជាបញ្ញវន្ត។

2-អ្នកជំនួយ៖ អ្នកការពារ ដែលជាកងទ័ព។

3-កម្មករ៖ អ្នកផលិតទំនិញ ផ្តល់សេវាកម្ម។

សមត្ថភាពប្រកបដោយភាពឈ្លាសវៃរបស់មនុស្សម្នាក់ នឹងកំណត់កិច្ចការខាង វណ្ណៈរបស់ខ្លួន។

ភាពស្រដៀងគ្នា បានកើតមានឡើងរវាងគំនិតខុងជឺ ឥណ្ឌាបុរាណ និងប្លាតុង។ តាមគំនិតទាំង៣នេះ សង្គម គួរតែត្រូវបានរៀបចំរចនាសម្ព័ន្ធ ទៅតាមឋានានុក្រម ជាមួយមនុស្សដែលមានប្រាជ្ញាបំផុត ស្ថិតនៅក្នុងតំណែងកម្រិតខ្ពស់បំផុតនៃអាជ្ញាធម៌។ ផ្ទុយទៅវិញ

---

[21] Plato, *Republic* (London: Folio Society, 2003; also see *Selected Dialogues of Plato: The Benjamin Jowett Translation* (New York: Modern Library, 2001)

សង្គម តាមបែបឋានានុក្រមបែបនេះ ពួកសូហ្វីស អះអាងថា អ្នកណាម្នាក់ ក៏អាចឡើងទៅដល់កម្រិតកំពូលបានដែរ ប្រសិនបើគេទទួលបានបច្ចេកទេស ដែលផ្តល់អំណាច ដល់ពួកគេបាន។

**ច-ការអប់រំដែលទាក់ទងដល់តួនាទីសង្គម**

ក្នុងការរៀបចំវណ្ណៈបុគ្គលម្នាក់ៗ នៅក្នុងសាធារណៈរដ្ឋ គួរទទួលបានការអប់រំ ដែល សមរម្យទៅតាមតួនាទីសង្គមរបស់គេ៖

1-អធិរាជទស្សនវិជ្ជា ដែលត្រូវបានគេអប់រំសម្រាប់ភាពជាអ្នកដឹកនាំ ក៏ទទួលខុសត្រូវផងដែរ សម្រាប់កំណត់អត្តសញ្ញាណអ្នក ដែលមានសមត្ថភាពខាងបញ្ញា ទៅតាមមនុស្សជំនាន់ក្រោយ ហើយរៀបចំឱ្យគេ ទៅតាមតួនាទីជោគវាសនា នាពេលខាងមុខ។

2-វណ្ណៈទី២ ដែលជាអ្នកចម្បាំង ជាអ្នកក្លាហានជាជាងអ្នកមានប្រាជ្ញា គួរតែត្រូវបានបណ្តុះបណ្តាលឱ្យការពារសាធារណរដ្ឋ ហើយនិងទទួលបទបញ្ជាពីអធិរាជទស្សនវិជ្ជា។

3-វណ្ណៈទី៣ និងជាវណ្ណៈធំជាងគេបំផុតគឺពួកកសិករ គួរត្រូវបានបណ្តុះបណ្តាល ជាកសិករ និងសិប្បករ។

ដោយមានការអប់រំមួយសម្រាប់ក្រុមនីមួយៗសាធារណរដ្ឋ បានត្រៀមរៀបចំសមាជិករបស់ខ្លួន សម្រាប់មុខងារដ៏សមរម្យរបស់គេ ដែលជាបន្តបន្ទាប់ បានរួមចំណែកដល់ភាពចុះសម្រុងគ្នា នៅក្នុងសហគមន៍ និងអនុវត្តមុខងារ ទៅតាមសមត្ថភាព។ ការរិះគន់ក្នុងសម័យទំនើបសព្វថ្ងៃនៃការរៀបចំសិស្សនៅក្នុងសាលារៀន អះអាងថា ឧបករណ៍សម្រាប់បិទបាំង ពិតជាមានបំណងបង្កើតឡើងវិញនូវស្ថានភាពវណ្ណៈ ដែលមានរួចហើយជាជាងលើកទឹកចិត្តចលនាក្នុងចំណោមវណ្ណៈសង្គមទាំងឡាយ។

**ឆ-ការអប់រំស្ត្រី**

មិនដូចពួកអាថែន ប្លាតុងជឿជាក់ថា ស្ត្រីគួរតែមានអភ័យឯកសិទ្ធិដូចគ្នា និងការទទួលខុសត្រូវស្មើនឹងបុរស[22]។ ស្ត្រីផងដែរ បានធ្លាក់ទៅក្នុងវណ្ណៈ៣ ដែលប្លាតុងបានដាក់ ចំពោះមនុស្ស។ ស្ត្រីដែលមានឥទ្ធិពលពុទ្ធិកម្រិតខ្ពស់អាចក្លាយជាសមាជិកនៃវរជនខាង ទស្សនវិជ្ជា ដែលសម្រាប់គ្រប់គ្រង។ អ្នកផ្សេងទៀត ដែលជាបញ្ញាជនជាន់ទាបជាង គួររៀបចំឱ្យមានឋានៈទាបជាង។ ដូចជាបុរសផងដែរ ស្ត្រីគួរទទួលបានការអប់រំ ឬការបណ្តុះបណ្តាល ដែលសមរម្យទៅនឹងសមត្ថភាព និងមុខរបរដែលបានកំណត់។

**ជ-ទារកដ្ឋាន ដែលរៀបចំដោយរដ្ឋ**

កម្មវិធីសិក្សារបស់ប្លាតុង សមស្របនឹងវត្ថុបំណងអប់រំ ទៅតាមឋានានុក្រមជាជាង ទៅតាមសមភាពសង្គម។ ដោយភ័យខ្លាចឪពុកម្តាយ បន្តមរតកភាពល្ងង់ខ្លៅ និងបុរេវិនិច្ឆ័យ ទៅឱ្យកូនប្លាតុងចង់ឱ្យកុមារមានការចិញ្ចឹមដោយអ្នកជំនាញខាងការមើលថែទាំកុមារ។ កុមារ ដែលត្រូវបានបំបែកចេញពីឪពុកម្តាយនោះ គួរត្រូវរស់នៅក្នុងកន្លែងមើលថែទាំកុមារ

[22] Robert S. Brumbaugh, Plato’s Ideal Curriculum and Contemporary Philosophy of Education, Educational Theory (Spring 1987), pp.169-177

របស់រដ្ឋ ដូច្នេះហើយ កុមារទទួលបានទម្លាប់ល្អ និងវិសុទ្ធកម្មភាពអាក្រក់ចេញៗ

**ឈ-កម្មវិធីសិក្សាជាមូលដ្ឋានរបស់ប្លាតុង**

ពីអាយុ៦ឆ្នាំដល់១៨ឆ្នាំ កុមារគួររៀននៅសាលា ជាកន្លែងដែលគេត្រូវសិក្សាតន្ត្រី និងកីឡាកាយសម្ព័ន្ធ។ តន្ត្រី តាមនិយមន័យរបស់ប្លាតុង គឺជាមុខវិជ្ជាទូលំទូលាយ ដែលត្រូវបានរាប់បញ្ចូលទាំងការអាន ការសរសេរ អក្សរសិល្ប៍ នព្វន្តសាស្ត្រ ការច្រៀងជាក្រុម និងការរាំ។

ក្រោយពេលចេះអាន និងសរសេរស្ទាត់ហើយ សិស្សគួរនឹងអានអក្សរសិល្ប៍ក្រិក និងឡាតាំង។ ប្លាតុង បានចាត់ទុកអក្សរសិល្ប៍ ជាកម្លាំងដ៏មានឥទ្ធិពលក្នុងការបង្កើតអត្តចរិត និងជឿជាក់ថា កុមារគួរតែអានកំណាព្យ និងរឿងដែលត្រូវយកជាគំរូភាពពិត ស្តាប់បង្គាប់ដល់អាជ្ញាធម៌ សេចក្តីក្លាហាន និងការគ្រប់គ្រងចិត្តរំភើប។

ក្រោយពេលដែលទទួលបានមូលដ្ឋាននព្វន្តសាស្ត្រច្បាស់លាស់ហើយ សិស្សនឹងអនុវត្តដោយខ្លួនគេ ទៅនឹងធរណីមាត្រសាស្ត្រ និងតារាវិទ្យា។

កីឡាកាយសម្ព័ន្ធ ដែលមានមុខងារខាងលំហាត់ប្រាណ មានប្រយោជន៍សម្រាប់ការហាត់ទ័ព ដូចជា ការចាក់សាប ការបាញ់ធ្នូ ការគប់លំពែង និងការជិះសេះ គឺត្រូវបានចាត់ទុកជារឿងសំខាន់បំផុត សម្រាប់ការកសាងអត្តចរិត និងការអភិវឌ្ឍខាងរាងកាយ។ ប្លាតុង ក៏បានរាប់បញ្ចូលក្បួនច្បាប់នៃការតមអាហារ និងអនាម័យ នៅក្នុងកម្មវិធីសិក្សារបស់គាត់។

**ញ-ការអប់រំនៅឧត្តមសិក្សា**

ពីអាយុ១៨ឆ្នាំ ដល់២០ឆ្នាំ សិស្សនឹងបន្តការហ្វឹកហាត់យោធា និងរាងកាយច្រើនថែមទៀត។ នៅអាយុ២០ឆ្នាំ អធិរាជទស្សនវិជ្ជានាពេលអនាគត នឹងត្រូវបានជ្រើសរើស សម្រាប់រៀននៅឧត្តមសិក្សា១០ឆ្នាំបន្ថែមទៀត ខាងគណិតវិទ្យា ធរណីមាត្រសាស្ត្រ តារាសាស្ត្រ តន្ត្រី និងវិទ្យាសាស្ត្រ។ នៅអាយុ៣០ឆ្នាំ អ្នកមានសមត្ថភាពខាងបញ្ញាទាប នៅក្នុងចំណោមក្រុមនេះ នឹងក្លាយទៅជាមន្ត្រីរាជការ (Civil servants)។ រីឯអ្នកដែលមានសមត្ថភាព បញ្ញាខ្ពស់បំផុត នឹងបន្តការសិក្សាទស្សនវិជ្ជាជាន់ខ្ពស់ជាងនេះទៀត ផ្នែកបរមត្ថវិទ្យា ការស្រាវជ្រាវរកគោលការណ៍ដែលបានពន្យល់តថភាពកម្រិតខ្ពស់បំផុត។ នៅពេលដែល ការសិក្សារបស់គេ ត្រូវបានបញ្ចប់ អធិរាជទស្សនវិជ្ជា នឹងចាប់ផ្តើមដឹកនាំកិច្ចការនយោបាយ និងយោធារបស់សាធារណរដ្ឋ។ នៅអាយុ៥០ឆ្នាំ អធិរាជទស្សនវិជ្ជា នឹងក្លាយជារដ្ឋបុរស ដែលមានវ័យចំណាស់។

**៥-៤-អារីស្តូត: ការអប់រំនៃសនិទានភាព**

សិស្សរបស់ប្លាតុង ឈ្មោះអារីស្តូត (៣៨៤-៣២២មុនគ.ស.) ជាគ្រូបង្រៀនសិស្សតែម្នាក់របស់ Alexander the Great។ អារីស្តូត បានបង្កើត Lyceum ជាសាលាទស្សនវិជ្ជាអាថែន ហើយបាននិពន្ធជាច្រើនផ្នែករូបវិទ្យា តារាសាស្ត្រ សត្វសាស្ត្រ រុក្ខសាស្ត្រ តក្កវិទ្យា សីល

វិទ្យា និងបរមត្ថវិទ្យា។ សីលវិទ្យា និងនយោបាយរបស់គាត់ បានពិនិត្យមើលការអប់រំ ដែលមានទំនាក់ទំនងទៅនឹងសង្គម និងរដ្ឋាភិបាល[23]។

**ក-តថភាពសត្យានុម័តិ** ( An Objective Reality )

វាមិនដូចអ្នកប្រៀនប្រដៅរបស់គាត់ ឈ្មោះប្លាតុង ដែលជឿថា តថភាព កើតមាន នៅក្នុងវិស័យគំនិតបរិសុទ្ធ។ អារីស្តូត យល់ថា តថភាព កើតមានជាសត្យានុម័តិ។ ថ្វីបើប្លាតុង បានបង្កើតទស្សនវិជ្ជាមនោនិយមក៏ដោយ ក៏អារីស្តូត បានបង្កើតទស្សនវិជ្ជាតថនិយមដែរ (ដែលមានសិក្សា នៅផ្នែកខាងក្រោយ)។

អារីស្តូត បានកត់សម្គាល់ឃើញថា វត្ថុ ឬរូបធាតុ កើតមាននៅខាងក្រៅចិត្តរបស់ មនុស្ស តែជឿថា តាមឥន្ទ្រីយារម្មណ៍ និងអរូបី យើងអាចទទួលបានចំណេះដឹងអំពីវា។ អារីស្តូត នៅតែអះអាងដោយទទូចថា មនុស្ស មានបញ្ញា គឺថាមពលដើម្បីគិត និងធ្វើវិចារ។ ក្នុងនាមជាសត្វដែលមានវិចារណញ្ញាណ គេមានសក្តានុពលយល់ដឹងនិងរស់នៅយោងទៅតាមច្បាប់ធម្មជាតិដែលគ្រប់គ្រងចក្រវាឡ។

**ខ-ឥន្ទ្រីយារម្មណ៍ជាប្រភពនៃចំណេះដឹង**

ចំពោះអារីស្តូត ការយល់ដឹងចាប់ផ្តើមចេញពីឥន្ទ្រីយារម្មណ៍ នៃវត្ថុរបស់អ្នកណាម្នាក់នៅក្នុងបរិស្ថាន។ ពីបទពិសោធនៃសរីរាង្គឥន្ទ្រិយ គេអាចបង្កើតបញ្ញត្តិអំពីវត្ថុ ឬរូបធាតុ។ ការបញ្ជាក់អះអាងរបស់អារីស្តូត ទៅលើបទពិសោធ តាមរយៈសរីរាង្គឥន្ទ្រិយ ដែលជាការចាប់ផ្តើមនៃការយល់ដឹង និងការបង្រៀន ដែលក្រោយមក ត្រូវបានអះអាងដោយអ្នកអប់រំ នៅសតវត្សទី១៨ និងទី១៩ ដូចជា Locke and Pestalozzi។

**គ-ការអប់រំជាការបណ្តុះសនិទានភាព**

***អារីស្តូត ស្តីពីការអប់រំ៖*** ក្នុងផ្នែកនយោបាយរបស់គាត់ អារីស្តូត អះអាងថា សហគមន៍ល្អ ស្ថិតនៅលើសនិទានភាពរបស់សមាជិក។ ប្រសិនបើការអប់រំ ដែលជាអ្នកបណ្តុះ សនិទានភាពនោះ ត្រូវបានធ្វេសប្រហែស ដូច្នេះ សហគមន៍ នឹងទទួលរងគ្រោះថ្នាក់។ ដូចជាប្លាតុង អារីស្តូត បានបែងចែកភាពខុសគ្នារវាងការអប់រំសេរី និងការបណ្តុះបណ្តាលបច្ចេកទេស។ អារីស្តូត បានមើលឃើញសិល្បៈសេរីថា ជាការពង្រីកនភាបាទរបស់មនុស្ស ញាណ និងការជ្រើសរើស និងគាត់បានមើលឃើញការបណ្តុះបណ្តាលវិជ្ជាជីវៈ ថាជារឿង មានតម្លៃ តាមដែនកំណត់របស់វាតែប៉ុណ្ណឹង។ ការពិភាក្សា នាសម័យទំនើបរវាងអ្នកអប់រំសេរី និងមុខរបរ ជាញឹកញាប់ធ្ងុះបញ្ចាំងបញ្ហាតែមួយ ដែលអារីស្តូត និងអ្នកទ្រឹស្តីដទៃទៀតបានពិនិត្យ មើល ហើយក្នុងនាមជាគ្រូម្នាក់ អ្នកអាចនឹងជួបប្រទះកំណែប្រែថ្មីនៃការពិភាក្សាតែមួយ នៅពេលដែលសិស្សសួរអ្នកពីមូលហេតុដែលគេគួរសិក្សាអ្វីមួយ

---

[23] Christopher Rowe and Sarah Brodie, *Aristotle: Nicomachean Ethics* (Oxford U.K.: Oxford University Press, 2002; also see Mary M. Spangler, *Aristotle on Teaching* (Lanham, Md.: University Press of America, 1998).

ដែលគេជឿជាក់ថា វានឹងមិនត្រូវបានប្រើប្រាស់។ អ្វីជាសនិទានកម្មរបស់អ្នក ដើម្បីបង្រៀនបំណិនពិតប្រាកដ និងមុខវិជ្ជាទាំងឡាយ តែមិនមែនមុខវិជ្ជាផ្សេងទៀត។

**ឃ-កម្មវិធីសិក្សារបស់អារីស្តូត**

អារីស្តូត បានផ្តល់ឱ្យមានការអប់រំជាកាតព្វកិច្ច។ ការអប់រំកុមារតូច គឺត្រូវមានការលេងសកម្ម ភាពខាងរាងកាយ និងរឿងនិទានដែលសមរម្យ។

កុមារពីអាយុ៧ឆ្នាំ ដល់១៤ឆ្នាំ ត្រូវរៀនលេខ និងការអាន សរសេរ និងទម្លាប់សីលធម៌សមរម្យ ដើម្បីត្រៀមរៀបចំពួកគេឱ្យសិក្សានាពេលអនាគតខាងសិល្បៈសេរី។ កម្មវិធី សិក្សារបស់គេ ក៏បានរាប់បញ្ចូលការអប់រំកាយ និងតន្ត្រី ដើម្បីបណ្តុះផ្នែកអជ្ឈាស្រ័យ ចិត្តរំភើបសមរម្យ។

ពីអាយុ១៥ឆ្នាំរហូតដល់២១ឆ្នាំ យុវជនត្រូវសិក្សាគណិតវិទ្យា ធរណីមាត្រសាស្ត្រ តារាសាស្ត្រ វេយ្យាករណ៍ វោហារសាស្ត្រ សីលវិទ្យា និងនយោបាយ។

នៅអាយុ២១ឆ្នាំ សិស្ស ត្រូវបន្តរៀនមុខវិជ្ជាខាងទ្រឹស្តីថែមទៀត ដូចជារូបវិទ្យា លោកធាតុវិទ្យា ជីវវិទ្យា ចិត្តវិទ្យា តក្កវិទ្យា និងបរមត្ថវិទ្យា។

**ង-តួនាទីតាមដែនកំណត់របស់ស្ត្រី**

ដោយជឿជាក់ថា ស្ត្រីមានប្រាជ្ញាអន់ជាងបុរស អារីស្តូត បានយកចិត្តទុកដាក់តែការអប់រំបុរសតែប៉ុណ្ណោះ។ ក្មេងស្រី ត្រូវបានគេអប់រំសម្រាប់តែឱ្យធ្វើការងារផ្ទះ និងតួនាទីចិញ្ចឹមកូនដែលចាំបាច់សម្រាប់ពេលអនាគត ជាប្រពន្ធ និងជាមាតា។

**ចចំណេះដឹងខាងបញ្ញត្តិដែលផ្អែកលើវត្ថុ**

ទ្រឹស្តីរបស់អារីស្តូតនៃចំណេះដឹងៈ អារីស្តូត ជាជនតថនិយម ខុសប្លែកពីប្លាតុង ជាជនមនោនិយម នៅក្នុងបញ្ញត្តិរបស់គាត់ស្តីពីចំណេះដឹង កើតឡើងពីវត្ថុជាជាងពីគំនិត ដែលកើតឡើងមុន នៅក្នុងចិត្ត។ យោលទៅតាមអារីស្តូត ចំណេះដឹង តែងតែអំពីវត្ថុ។ ការអប់រំ ផ្តោតទៅលើការចាត់ថ្នាក់របស់វត្ថុ ទៅជាបញ្ហាប្រធានបទ ឬមុខវិជ្ជា។

ឧទាហរណ៍៖ ប្រសិនបើអ្នកកំពុងតែបង្រៀនកូតគ្រាមសាស្ត្រ ដោយប្រើប្រាស់វិធីអារីស្តូតនោះ អ្នកអាចបង្រៀន អំពីដើមឈើទាំងឡាយជាថ្នាក់មួយ ដែលជាប្រភេទទូទៅមួយ ក្នុងតថភាពកូតគ្រាម សាស្ត្រ និងអំពីដើមឈើជាពិសេស ដែលជាសមាជិកមួយៗនៃថ្នាក់នេះ។

**ឆ-ឥទ្ធិពលដែលស្ថិតនៅរបស់អារីស្តូត**

គោលដៅបឋមរបស់សាលារៀនអារីស្តូត គឺត្រូវបណ្តុះសនិទានភាព។ ក្នុងនាមជាស្ថាប័នសិក្សាសាលារៀនគួរ តែផ្តល់កម្មវិធីសិក្សា ទៅតាមបញ្ហាប្រធានបទ ដែលបានកំណត់ដោយផ្អែកលើមុខវិជ្ជាវិទ្យាសាស្ត្រ និងមានខ្លឹមសារ។ គ្រូ ត្រូវតែមានចំណេះដឹង ជំនាញទៅលើមុខវិជ្ជារបស់ខ្លួន និងមានជំនាញនៅក្នុងការជំរុញទឹកចិត្តសិស្ស និងផ្ទេរចំណេះដឹងទៅឱ្យសិស្ស។

ទស្សនវិជ្ជារបស់អារីស្តូត មានខ្លឹមសារដ៏សំខាន់ ទៅលើការអប់រំ លោកខាងលិច។ ក្នុងចំណោម លទ្ធិរបស់សាសនាគ្រិស្ត វាក្លាយជាមូលដ្ឋានគ្រឹះ នៃការអប់រំ សិក្សា នៅមជ្ឈិមសម័យ (ខ្លឹមសារ លំអិតនឹងបកស្រាយនៅពេលក្រោយ)។

### ៥-៥-អ៊ីសូក្រាតៈ សិល្បៈនៃការថ្លែងសុន្ទរកថា និងវោហារសាស្ត្រ

អ្នកវោហារសាស្ត្រជនជាតិក្រិក ឈ្មោះ Isocrates (436-388 B.C.) ជាមនុស្សដ៏សំខាន់ សម្រាប់ទ្រឹស្តីអប់រំ ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ លើសគេឯង ដែលសង្កត់ធ្ងន់ទៅ លើចំណេះដឹង និងបំណិនវោហារសាស្ត្រ[24]។ ទ្រឹស្តីរបស់គាត់ ប្រកាន់ តាមផ្លូវកណ្តាល រវាងទំនាស់នៃពួកសូហ្វីស និងប្លាតុង។ អភិប្រាយរបស់អ៊ីសូក្រាត ប្រឆាំងនឹង ពួកសូហ្វីស បានពន្យល់នូវវិធី ដែលបានប្រើ ប្រាស់ក្នុងសាលារៀននេះ។

### ក-ការសង្កត់ធ្ងន់ទៅលើវោហារសាស្ត្រ

អ៊ីសូក្រាត ចាត់ទុកគោលដៅបឋមនៃការ អប់រំថា ត្រូវតែត្រៀមរៀបចំរដ្ឋបុរស ឱ្យមានការ គិតច្បាស់ លាស់ ប្រកបដោយវិចារណញ្ញាណ និងសច្ចភាព។ គាត់ជឿជាក់ថា កំណែទម្រង់ស៊ីវិល ទាមទារឱ្យមានការអប់រំអ្នកដឹកនាំ ដែល ប្រកបដោយគុណធម៌ ដែលអាចជាអ្នករដ្ឋបាល មានប្រសិទ្ធភាព។ ក្នុងចំណោមការសិក្សាដោយ សេរីIsocrates យល់ថា វោហារសាស្ត្រ ដែលបាន កំណត់ន័យថា ជាការបង្ហាញគំនិតប្រកបដោយ វិចារណញ្ញាណនោះ គឺជារឿងសំខាន់ បំផុតក្នុង ការបណ្តុះសីលធម៌ និងភាពជាមេដឹកនាំនយោបាយ។ ការអប់រំវោហារសាស្ត្រ គួរតែផ្សំបញ្ចូលគ្នាសិល្បៈ និងវិទ្យាសាស្ត្រ និងទំនាក់ទំនងប្រកបដោយ ប្រសិទ្ធភាព។ អ្នកជំនាញ ខាងថ្លែងសុន្ទរកថាដ៏ មានតម្លៃ គួរតែអះអាង សម្រាប់បុព្វហេតុកិត្តិយស ដែលបានជំរុញដល់ កុសល សាធារណៈ។ តាមគោលវិធីខាងលើ អ្នកមានជំនាញខាងថ្លែង សុន្ទរកថា នឹងបញ្ចុះបញ្ចូលមនុស្សឱ្យធ្វើតាម គោលនយោបាយដ៏ល្អ។ Isocrates ប្រឆាំងនឹងការ បង្រៀនរបស់ពួក សូហ្វីសនៃវោហារសាស្ត្រ ដែល គ្រាន់តែជាផ្លូវបញ្ចុះបញ្ចូលដដែលៗ ឬ បច្ចេកទេសទំនាក់ទំនងសាធារណៈ។

សិស្សរបស់Isocrates ដែលបានសិក្សា នៅ សាលារបស់គាត់រយៈពេល៤ឆ្នាំនោះ បានសិក្សា វោហារសាស្ត្រ នយោបាយ ប្រវត្តិសាស្ត្រ និងសីល វិទ្យា។ ពួកគេបានវិភាគ និងត្រាប់តាមសិល្បៈនៃ ការថ្លែងសុន្ទរកថាគំរូ និងប្រតិបត្តិការនិយាយ ជា សាធារណៈ។ ក្នុងនាមជាគ្រូគំរូម្នាក់ Isocrates ជឿ ជាក់ថា គាត់ទទួលខុសត្រូវ ចំពោះការជះឥទ្ធិពល ដល់សិស្ស តាមការបកស្រាយផ្ទាល់របស់គាត់នៃ ចំណេះដឹង បំណិន និងចរិយាខាងសីលវិទ្យា។

### ខ-ការធ្វើតុល្យភាពប្លាតុង និងពួកសូហ្វីស

ទោះបីជា Isocrates ប្រឆាំងនឹងកាលានុវត្ត និយមដ៏កម្រោលរបស់ពួកសូហ្វីស គាត់បាន បដិសេធការអះអាងរបស់ប្លាតុងដែលថា ការអប់រំ

[24] Ekaterina V.Haskins. *Logos and Power in Isocrates and Aristotle* (Columbbia: University of South Carolina Press, 2004), also see Gerald L. Gutek, *A History of the Western Educational Experience* (Prospect Heights, III.: Waveland Press, 1995), pp52-54.

មានតែទ្រឹស្តីសុទ្ធ និងអរូបី។ ចំពោះការអប់រំ Isocrates បានរួមចំណែកដល់សេវាកម្មសាធារណៈ ដែលត្រូវបានដឹកនាំដោយចំណេះដឹង។ Isocrates មានឥទ្ធិពលទៅលើប្រពៃណីខាងវោហារសាស្ត្រ ក្នុងការអប់រំ ជាពិសេស អ្នកទ្រឹស្តីអប់រំរបស់រ៉ូម៉ាំង ឈ្មោះQuintilian។ ដោយទទួលស្គាល់វិសាលភាព វោហារសាស្ត្ររបស់មនុស្សជាតិ Isocrates ក៏បាន រួមចំណែកដល់ឧត្តមគតិរបស់មនុស្ស ដែលមាន ការអប់រំដោយសេរី។

## ៥-៦-ការអប់រំ នៅក្រុងរ៉ូមបុរាណ

នៅពេលដែលវប្បធម៌ និងការអប់រំរបស់ក្រិក កំពុងតែបានអភិវឌ្ឍនៅសមុទ្រមេឌីទែរ៉ាណេប៉ែកខាងលិចនោះ ពួករ៉ូម៉ាំង កំពុងតែពង្រីងដំហរខាងនយោបាយ នៅលើឧបទ្វីបអ៊ីតាលី (Italian Peninsula) និងពាសពេញសមុទ្រមេឌីទែរ៉ានេប៉ែកខាងលិច។ នៅក្នុងចលនារបស់គេ ពីសាធារណរដ្ឋដ៏តូច ទៅជាចក្រភពដ៏ធំនោះ ពួករ៉ូម៉ាំងបានផ្តើមកាន់កាប់ឬត្រួតត្រាជាមុន ដោយសង្គ្រាមនិងនយោបាយ។ នៅពេលមួយនោះ ពួកគេបានក្លាយទៅជាអំណាចចក្រភពនោះ ពួកគេបានផ្ចង់អារម្មណ៍ទៅលើរដ្ឋបាល ច្បាប់ និងការទូត ដែលចាំបាច់ដល់ការថែរក្សាចក្រភព។ ដោយមូលហេតុដែលគេបានកត់សម្គាល់ឃើញថា ពួកក្រិក យកចិត្តទុក ដាក់តែទៅលើទស្សនវិជ្ជានោះ ពួករ៉ូម៉ាំងបែរជាផ្តោតអារម្មណ៍ ទៅលើការអប់រំ អ្នកនយោបាយជាក់ស្តែង អ្នករដ្ឋបាល ដែលមានសមត្ថភាព និងជំនាញទូទៅ។

### ក-ការចូលរៀន

នៅក្នុងប្រទេសក្រិកបុរាណ មានតែពួករ៉ូម៉ាំងមួយភាគតូចប៉ុណ្ណោះ ដែលបានទទួលការអប់រំក្នុងប្រព័ន្ធ។ ការអប់រំទុក សម្រាប់តែមនុស្ស ដែលមានលុយបង់ថ្លៃសាលារៀន និងពេលវេលាសិក្សា។

### ខ-សាលាបឋមសិក្សា និងមធ្យមសិក្សា

ដោយហេតុថា ក្មេងស្រីវណ្ណៈខ្ពស់ ជារឿយៗ បានរៀនអាន និងសរសេរ នៅផ្ទះ ឬត្រូវបានបង្រៀនដោយគ្រូបង្រៀនសិស្សទោលនោះ ក្មេងប្រុស ដែលមកពីគ្រួសារទាំងនេះ បានចូលរៀន នៅសាលាបឋមសិក្សា (Ludus) ហើយបន្ទាប់មកមធ្យមសិក្សា ដែលត្រូវបានបង្រៀន ដោយគ្រូដែលបង្រៀនវេយ្យាករណ៍ ក្រិក និងឡាតាំង។ ក្មេងប្រុស ត្រូវបានគេជូនទៅរៀន នៅសាលារៀនទាំងនេះ ដោយពួកទាសករក្រិកដែលមានការអប់រំ ត្រូវបានគេហៅថា Pedagogues (=Teachers) ដែលពាក្យគរុកោសល្យ(Pedagogy) មានន័យថា សិល្បៈនៃការបង្រៀន បានក្លាយចេញពីពាក្យនេះឯង។

### គ-ឧត្តមគតិនៃវាគ្មិន

ឧត្តមគតិអប់រំរបស់ពួករ៉ូម ត្រូវបានបញ្ជាក់ដោយវាគ្មិន។ វាគ្មិនរ៉ូម៉ាំង ដែលប្រកបដោយ ឧត្តមគតិ គឺជាមនុស្ស ដែលមានការអប់រំពីជីវិតសាធារណៈយ៉ាងទូលំទូលាយ និងដោយសេរី ដូចជា សមាជិកព្រឹទ្ធសភា មេធាវី គ្រូបង្រៀន មន្ត្រីរាជការ និងអ្នកនយោបាយ។ ដើម្បីពិនិត្យ មើលឧត្តមគតិនៃសិល្បៈខាងការថ្លែង

សុន្ទរកថារបស់រ៉ូម៉ាំង យើងត្រឡប់ទៅមើល Quintilian។

**Quintilian** ជំនាញច្បាស់លាស់នៃការថ្លែងសុន្ទរកថា ៖ Marcus Fabias Quintinius (A.D. 35-95) ឬហៅថា Quintilian គឺជាវោហារសាស្ត្រវិទូ ដែលត្រូវបានគេទទួលស្គាល់ដោយកម្រិត ខ្ពស់បំផុតរបស់ចក្រភពរ៉ូម៉ាំង។ អធិរាជ បានតែងតាំងគាត់ទៅដល់កម្រិតប្រធាន នៃវោហារសាស្ត្រឡាតាំងទីមួយ។

**ឃ-ការបង្រៀនដោយផ្អែកលើដំណាក់កាលនៃការលូតលាស់**

Quintilian's Institutio Oratoria ដែលជាអត្ថាធិប្បាយអប់រំជាប្រព័ន្ធ បានរាប់បញ្ចូល៖

1-ការអប់រំដែលជាបរិវច្ឆ័ណ ដើម្បីសិក្សាវោហារសាស្ត្រ។

2-ទ្រឹស្តីអប់រំ និងវោហារសាស្ត្រ។

3-ការប្រតិបត្តិនៃការនិយាយជាសាធារណ: ឬការថ្លែងទៅកាន់ទស្សនិកជន។

Quintilian បានបង្កើតចំណុចអប់រំដ៏សំខាន់ ដែលការបង្រៀន គួរតែផ្អែកទៅលើដំណាក់កាលនៃការលូតលាស់ និងការអភិវឌ្ឍមនុស្ស។ ដោយការប្រមើលមើលការយកចិត្តទុកដាក់របស់គ្រូសម័យទំនើប នៃភាពខុសគ្នារបស់សិស្សម្នាក់ៗនោះ គាត់បានផ្តល់ដំបូន្មានថា ការបង្រៀន គួរតែមានភាពសមរម្យដល់ភាពត្រៀមជាស្រេច និងបំណិនរបស់សិស្ស។ គាត់បានបញ្ជាក់នូវសារ: សំខាន់នៃវ័យដើមកុមារភាពក្នុងការបង្កើតអាកប្បកិរិយា ហើយគាត់បានផ្តល់ យោបល់ថា គ្រូបង្រៀនត្រូវជំរុញទឹកចិត្តសិស្ស ដោយធ្វើឱ្យការសិក្សា មានការចាប់អារម្មណ៍ និងការទាក់ទាញ។

សម្រាប់ដំណាក់កាលដំបូង ពីពេលកើតរហូតដល់អាយុ៧ឆ្នាំ នៅពេលដែលកុមារ កំពុងមានសន្ទុះចិត្ត និងយកចិត្តទុកដាក់ជាមួយនឹងតម្រូវការ និងចំណង់ភ្លាមៗនោះ គាត់បាន ផ្តល់ដំបូន្មានដល់ឪពុកម្តាយ ឱ្យចេះជ្រើសរើសមេដោះ គ្រូបង្រៀន ដែលមានការបណ្តុះបណ្តាលល្អ និងនិយាយបានត្រឹមត្រូវនិងមិត្តភ័ក្តិ សម្រាប់កុមារផង។

**ខ-ការអាន និងការសរសេរ**

ក្នុងដំណាក់កាលទី២នៃការអប់រំរបស់ Quintilian ពីអាយុ៧-១៤ឆ្នាំ កុមារគួររៀនពីបទពិសោធដែលទាក់ទងដល់ឥន្ទ្រីយារម្មណ៍ បង្កើតគំនិតច្បាស់លាស់ និងបណ្តុះបណ្តាលលំនឹករបស់គេ។ ឥឡូវនេះ គេរៀនសរសេរភាសា ដែលគេចេះនិយាយរួចហើយ។ គ្រូបង្រៀនដំបូង (litterator) ដែលបានបង្រៀនអាន និងសរសេរ នៅបឋមសិក្សានោះ ត្រូវតែមានអត្តចរិតថ្លៃថ្នូរ និងមានសមត្ថភាពបង្រៀន។ ការបង្រៀនខាងអំណាន និងសំណេរ គួរតែយឺតៗ និងហ្មត់ចត់ ហើយកុមារ គួររៀនអក្ខរក្រម ដោយប្រើប្រាស់លំដាប់អក្សរធ្វើពីភ្លុក។ ដូចជា Montessori ច្រើន សតវត្សក្រោយមក Quintilian បានផ្តល់ដំបូន្មានថា កុមាររៀនសរសេរអក្សរ ដោយតាមដានរូបរាងតួអក្សរ។ ដោយប្រមើលមើលការអប់រំសម័យទំនើប គាត់បានអះអាងថា សាលារៀនសព្វថ្ងៃនេះ រាប់បញ្ចូលទាំងការចេញលេង ដើម្បីលេងល្បែង និង

ការកម្សាន្តផ្សេងៗ ដើម្បីឱ្យសិស្សមានកម្លាំង និងថាមពលថ្មីឡើងវិញ។

**ច-ការសិក្សាសិល្បៈសេរី**

*សម្រាប់ដំណាក់កាលទី៣ នៃការអប់រំនេះ ពីអាយុ១៤-១៧ឆ្នាំ បានសង្កត់ធ្ងន់ទៅលើសិល្បៈសេរី។ សិស្សបានសិក្សាវេយ្យាករណ៍ក្រិក និងឡាតាំង អក្សរសិល្ប៍ ប្រវត្តិវិទ្យា ទេវកថា វិទ្យាដោយប្រើភាសា និងវប្បធម៌ទាំង២។ សិស្សក៏បានសិក្សាផងដែរនូវតន្ត្រី ធរណីមាត្រសាស្ត្រ តារាសាស្ត្រ និងកីឡាកាយសម្ព័ន្ធ។*

**ឆ-ការសិក្សាវោហារសាស្ត្រ**

*វាគ្មិនសម្រាប់ពេលអនាគត ទទួលបានការសិក្សាខាងវោហារសាស្ត្រ ជាដំណាក់កាលទី៤ ពីអាយុ១៧-២៤ឆ្នាំ។ ក្នុងការសិក្សាវោហារសាស្ត្រ* Quintilian*រាប់បញ្ចូលទាំង វិនាដសាស្ត្រ កំណាព្យ ច្បាប់ ទស្សនវិជ្ជា ការនិយាយជាសាធារណៈ ការថ្លែងទៅកាន់ទស្សនិកជន និងការពិភាក្សា*[25]*។ ការថ្លែងទៅកាន់ទស្សនិកជន ដែលជាលំហាត់និយាយជាប្រព័ន្ធ គឺមានសារៈសំខាន់ណាស់។ ក្រោយពេលត្រៀមរៀបចំបានសមរម្យ វាគ្មិនថ្មីៗថ្លែងទៅកាន់ទស្សនិកជន ជាសាធារណៈ នៅលើវេទិកា ហើយបន្ទាប់មកត្រឡប់ទៅរកវោហារសាស្ត្រវិទូ សម្រាប់ការរិះគន់ ទៅតាមជំនាញ។ គ្រូបង្រៀន បានកែកំហុសសិស្ស ដោយមានសុកវិនិច្ឆ័យពីអ្នកជំនាញ ដោយ មានអំណាត់ ជំនាញ ដោយសុទ្ធនៈ និងការពិចារណា។*

**៥-៧-ការរួមចំណែករបស់ក្រិក និងរ៉ូម៉ាំង ចំពោះការអប់រំលោកខាងលិច**

*សិល្បៈសេរីៈ ការអប់រំ និងវប្បធម៌លោកខាងលិច បានទទួលកេរដំណែលដ៏ច្រើន លើសលុបពីក្រិក និងរ៉ូមបុរាណ។ ភាគច្រើននៃរចនាសម្ព័ន្ធអប់រំ និងវប្បធម៌ ដែលបង្កើតបាន ជាអរិយធម៌លោកខាងលិច បានអភិវឌ្ឍក្នុងក្រិក និងរ៉ូមបុរាណ។ ដោយមានការជឿជាក់ថា វាអាចធ្វើទៅបាន ដើម្បីបណ្តុះឧត្តមភាពរបស់មនុស្ស ពួកក្រិក និងរ៉ូម៉ាំង បានផ្តល់ការអប់រំនូវមុខងារដ៏សំខាន់ នៅក្នុងសុខុមាលភាពនយោបាយសង្គម។ ទោះជាយ៉ាងណាក្តី ការប្រតិបត្តិការអប់រំ រ៉ូម៉ាំងក្រិកមួយចំនួន ដោយរាប់បញ្ចូលទាំងភាពខុសគ្នា រវាងការអប់រំសេរី និងការបណ្តុះបណ្តាលវិជ្ជាជីវៈ បាននាំទៅដល់វិវាទពិសេស ដែលបានស្ថិតនៅក្នុងប្រវត្តិសាស្ត្រលោកខាងលិច។*

*គំនិតជាច្រើននៃពួកក្រិក និងរ៉ូម៉ាំង បានជះឥទ្ធិពលភាពមានវិជ្ជាជ្រៅជ្រះ ដល់ពួកអារ៉ាប់ ដែលបានរក្សាទុក និងបានបកប្រែវា។ នៅពេលដែលពួកអឺរ៉ុប បានពើបប្រទះភាពមានវិជ្ជាជ្រៅជ្រះរបស់អារ៉ាប់ គំនិតទាំងនេះ ត្រូវបានផ្ទេរទៅកាន់អឺរ៉ុប ហើយបន្ទាប់មកដល់វប្បធម៌អាម៉េរិក។*

**៦-អ៊ីស្លាមៈ ការសិក្សាពីអារ៉ាប់ និងការអប់រំ**

*អរិយធម៌អ៊ីស្លាម ដែលមានប្រភពពីអារ៉ាប់ បានក្លាយជាកម្លាំងអប់រំ និងវប្បធម៌សកលតាមបំណិន ដើម្បីស្រូបទាញ បកស្រាយឡើងវិញ និងផ្ទេរចំណេះដឹង ពីតំបន់មួយនៅក្នុងពិភព*

[25] James J. Murphy, ed., *Quintilian on the Teaching of Speaking and Writing* (Cabondale: Southern Illinois University Press, 1987)

លោកទៅតំបន់មួយទៀត[26]។ ដើមកំណើតវប្បធម៌អ៊ិស្លាម បានចាប់ផ្ដើមជាមួយម៉ូហាមេត Mohammed (569-632) អ្នកកែទម្រង់សាសនាជនជាតិអារ៉ាប់ និងជាអ្នកញ៉ាំងឱ្យផ្លាស់សាសនា (proselytizer)។ Mohammed បានចាប់ផ្ដើមបេសកកម្មសាសនា នៅអារ៉ាប់ក្នុងទីក្រុងម៉ិកកា (Mecca) នៅឆ្នាំ៦១០ ដែលជាកន្លែងគាត់បានទេសនាចាំបាច់សម្រាប់កុក្កុច្ចៈ និងការរស់នៅដោយមានសីលធម៌ និងទៀងត្រង់។ បន្តិចម្ដងៗ គាត់បានរៀបចំគំនិតរបស់គាត់ទៅជាអ៊ិស្លាម ដែលជាសាសនាថ្មីមួយ។ សព្វថ្ងៃនេះ អ៊ិស្លាម ជាជំនឿខាងសាសនា ដែលមានចំនួនប្រជាជន ១/៨ ក្នុងពិភពលោក។ វាជាសាសនា ដែលបានគ្របដណ្ដប់ក្នុងប្រទេសអារ៉ាប់ទាំងឡាយ នៅមជ្ឈិមបូព៌ា និងអាហ្វ្រិកខាងជើង ហើយឥទ្ធិពលរបស់វា បានរាលដាលដល់ឥណ្ឌូនេស៊ី ម៉ាឡេស៊ី និងប៉ាគីស្ថាន ព្រមទាំងប្រទេសផ្សេងៗទៀត នៅទ្វីបអាស៊ី។ លើសពីនេះទៀត ជនម៉ូស្លីម ដែលជាអ្នកគោរពសាសនាអ៊ិស្លាម បានរស់នៅក្នុងប្រទេសជាច្រើនពាសពេញពិភពលោក ទោះបីជាញឹកញាប់បានក្លាយជាជនជាតិភាគតិចក៏ដោយ។ ដោយត្រូវបានគេគោរពយ៉ាងជ្រាល ជ្រៅថាជាព្យាការី សិស្សរបស់ Mohammed បានជឿជាក់ថា គាត់បាននិយាយដល់ពិភពលោក ដែលបានលាតត្រដាងដោយ Allah ឬព្រះ (God) ដែលត្រូវបានកត់ត្រាក្នុងគម្ពីរកូរ៉ាន(Koran)។ ដោយត្រូវបានសរសេរជាភាសាអារ៉ាប់ គម្ពីរកូរ៉ាន មិនគ្រាន់តែក្លាយជាសៀវភៅសាសនាដ៏ពិសិដ្ឋបំផុតរបស់អ៊ិស្លាមប៉ុណ្ណោះទេ ប៉ុន្ដែ ថែមទាំងជាប្រភពច្បាប់ និងសីលវិទ្យាអាជ្ញាព្រឹត្តផង ដែរក្នុងអារ៉ាប់ និងប្រទេសកាន់សាសនាអ៊ិស្លាមផងដែរ។ គម្ពីរកូរ៉ានភាគច្រើន បានរួមចំណែក ដល់សុកវិនិច្ឆ័យនៃការរួបរួមវប្បធម៌អ៊ិស្លាម និងអារ៉ាប់។ នៅពេលមួយនោះ បក្សសម្ព័ន្ធអារ៉ាប់ ដែលមានការឈ្លោះប្រកែកគ្នានោះ បានរួបរួមគ្នា នៅក្រោមទង់នៃការពង្រីកសាសនាអ៊ិស្លាម ពាសពេញពិភពលោក។

ត្រឹមឆ្នាំ៦៦១ កងកម្លាំងអារ៉ាប់ បានកាន់កាប់ និងបង្កើតសាសនាអ៊ិស្លាម ជាសាសនាផ្លូវការនៅប្រទេស Palestine, Syria, Persia, and Egypt។ ទីក្រុង Bagdad, Cairo, Damacus, and Cordoba បានក្លាយជាមជ្ឈមណ្ឌលដ៏មានកិត្តិនាមនៃការអប់រំ និងវប្បធម៌អ៊ិស្លាម។ ក្រុងបាដាដ ដែលជាមជ្ឈមណ្ឌលអប់រំដ៏ធំមួយនោះ ជាកន្លែងដែលអ្នកប្រាជ្ញពួកអារ៉ាប់ ក្រិក អ៊ីរ៉ង់ និងជ្វីហ្វ បានផ្លាស់ប្ដូរគំនិតគ្នា។

បន្ទាប់មក សាវ័ករបស់ Mohammed បានបន្តពង្រីកឥទ្ធិពលសាសនាអ៊ិស្លាម តាមរយៈសញ្ជ័យ និងកំណែប្រែថ្មី។ ក្រោយពេលវាយដណ្ដើមបានទ្វីបអាហ្វ្រិកខាងជើង អំណាចអារ៉ាប់លាតសន្ធឹងដល់អេស្ប៉ាញ។ នៅទីនោះ ជនអារ៉ាប់អ៊ិស្លាមនិងពួកអ្នកកាន់សាសនាគ្រិស្តលោក ខាងលិច បានតស៊ូប្រយុទ្ធដើម្បីអំណាច និងទឹកដី ប៉ុន្ដែក៏បានខ្ចីគំនិតពីគ្នាទៅវិញ ទៅមក[27]។ រាជាណាចក្រអ៊ិស្លាម (Moorish)នៃប្រទេសអេស្ប៉ាញ

[26] Malise Ruthven, *Islam in the World* (New York: Oxford University Press, 2000)

[27] Http://www.islamicity.com/mosque/ihame/sec5.htm (09/25/3003), pp.1-2

បានបន្តរហូតដល់ឆ្នាំ១៤៩២ នៅពេលដែលពួកគេត្រូវបានវាយដណ្តើម ដោយពួកសត្រូវនៃប្រទេសអេស្ប៉ាញ ដែលកាន់សាសនា គ្រិស្ត[28] ក្នុងអំឡុងពេលនៃពួក Moorish, Cordoba ដោយមានប្រជាជនចំនួន ៥០០,០០០ នាក់ ព្រះវិហារម៉ូស៧០០ និងបណ្ណាល័យចំនួន៧០ បានក្លាយជាមជ្ឈមណ្ឌលអប់រំ និងវប្បធម៌អារ៉ាប់ ដែលនាំមុខគេ[29]។

អ្នកប្រាជ្ញអ៊ីស្លាម បានបកប្រែអត្ថបទចេញពីអ្នកនិពន្ធក្រិកបុរាណ ដូចជា Aristotle, Euclid, Archimedes, Hippocrates ទៅជាភាសាអារ៉ាប់។ ស្នាដៃដែលបានបកប្រែ មានសារៈ សំខាន់ដល់ការអប់រំអ៊ីស្លាម ហើយតាមរយៈការទាក់ទងគ្នារវាងពួកអារ៉ាប់ និងពួកអឺរ៉ុប ត្រូវបាននាំយកទៅប្រើប្រាស់ទៅជាការអប់រំលោកខាងលិច។ ជាពិសេស Ibn-Rushd, or Averroës (1126-1198) បាននិពន្ធបទអត្ថាធិប្បាយដ៏សំខាន់ ទៅលើអារីស្តូតដែលជះឥទ្ធិពលដល់ អ្នកអប់រំពួកអឺរ៉ុប នៅមជ្ឈិមសម័យ។

ភាពមានវិជ្ជាជ្រៅជ្រះខាងអ៊ីស្លាម បាននាំទៅដល់ភាពជឿនលឿនខាងតារាសាស្ត្រ គណិតវិទ្យា និងវេជ្ជសាស្ត្រ។ ខាងគណិតវិទ្យា អ្នកប្រាជ្ញអារ៉ាប់ បានចាប់ប្រើប្រព័ន្ធលេខពីឥណ្ឌា ប៉ុន្តែបានបង្កើតបន្ថែមលេខសូន្យដ៏ចាំបាច់។ នវានុវត្តន៍នេះ បានបង្កើតភាពងាយ ស្រួលក្នុងការជំនួសប្រព័ន្ធឡាតាំង ដែលទើសទែង។

នៅសតវត្សទី២១ អន្តរកម្មបានបន្ត រវាងវប្បធម៌អ៊ីស្លាម និងអារ៉ាប់ និងពិភពលោកខាងលិច។ ទោះបីជាមានទំនាស់ នាពេលថ្មីៗយ៉ាងខ្លាំងក៏ដោយ រវាងលោកខាងលិច ជាពិសេស សហរដ្ឋអាម៉េរិក និងអារ៉ាប់ និងក្រុមអ៊ីស្លាម ក៏ការជួបប្រទះជាវិជ្ជមានថែមទៀត បានកើតឡើងរវាងពួកអារ៉ាប់ និងអាម៉េរិក។ ជាពិសេស ពួកអាម៉េរិកជាច្រើន កំពុងបានការយកចិត្តទុកដាក់ និងសិក្សាថែមទៀត អំពីការរួមចំណែកនៃអរិយធម៌អារ៉ាប់ និងសាសនាអ៊ីស្លាម ចំពោះវប្បធម៌ពិភពលោក។

ក្នុងលទ្ធផលនៃការវាយប្រហារ ទៅលើមជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០០១ និងការឆ្លើយតបរបស់សហរដ្ឋអាម៉េរិកជាមួយការយកចិត្តទុកដាក់លើសង្គ្រាម ភេរវកម្មនិយម បានកើនឡើង ចំពោះការសិក្សាវប្បធម៌អារ៉ាប់ និងសាសនាអ៊ីស្លាម។ ទោះបីជាពួកភេរវជនមួយចំនួន ត្រូវបានកំណត់អត្តសញ្ញាណ ថាមានសញ្ជាតិមកពីប្រទេសអារ៉ាប់ ក៏ដោយក៏សកម្មភាពទាំងឡាយតិចតួចមិនបានតំណាងការគិតដល់ជនអារ៉ាប់ទាំងអស់ និងផ្ទុះបញ្ចាំងដល់ជំនឿអ៊ីស្លាម។ ដើម្បីយល់ដឹងពីការផ្លាស់ប្តូរកម្លាំងពិភពលោកនោះ សាលារៀន និងមហាវិទ្យាល័យអាម៉េរិក កំពុងយកចិត្តទុកដាក់ថែមទៀត ដើម្បីរាប់បញ្ចូលមុខវិជ្ជាសិក្សាទៅលើប្រជាជន និងវប្បធម៌អារ៉ាប់ និងសាសនាអ៊ីស្លាម។

[28] Mortimer Chamber, Raymont Grew, David Herlihy, Theodore Rabb, and Isser Woloch, *The Western Experience* (New York: Knopf, 1983), pp.228-235.

[29]Http:// www.islamicity.com/mosque/ihame/sec5.htm (09/25/3003), pp.1-2

**ឯកសារយោង**


1-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.

2-Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.

3-Barzun, Jacques. *From Dawn to Decadence: 500 Years of Western Cultural Life, 1500 to the Present.* New York: HarperCollins, 2001.

4-Black, Robert. *Humanism and Education in Medieval and Renaissance Italy:Tradition and Innova tion in Latin Schools from the Twelfth to the Fifteenth Century.* New York:Cambridge Uni versity Press, 2001.

5-Gutek, Gerald. *Historical and Philosophical Foundations of Education: A Biographical Introduction.* Columbus, Ohio: Merrill/Prentice Hall, 2005.

6-Gutek, Gerald. *Historical and Philosophical Foundations of Education:Selected Readings.* Columbus, Ohio: Merrill/Prentice Hall, 2001.

7-Hanson, Victor D, and Heath, John. *Who Killed Homer? The Demise d of Classical Education and the Recovery of Greek Wisdom.* New York: Encounter Books, 2001.

8-Lascarides, V.Celia, and Hinitz, Blythe F. *History of Early Childhood Education.* New York:Falmer Press, 2000.

9-Palmer, Joy A, Cooper, David E., and Bresler, Liora, eds. *Fifty Major Thinkers on n Education:From Confucius to Dewey.* New York: Routledge, 2001.

10-Ruthven, Malise. *Islam in the World.* New York: Oxford University Press, 2000.